ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# ISSUE OF SECURITIES IN PHNOM PENH WATER SUPPLY AUTHORITY

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ISSUE OF SECURITIES IN PHNOM PENH WATER SUPPLY AUTHORITY

សាស្ត្រាចារ្យណែនាំ៖ ប៉ូ ជុនហេង

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**
**ប្រធានបទៈ ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | ប៉ូ ជុនហេង |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល ៤ ឆ្នាំ រួចមកក្រុមយើងខ្ញុំ បានទទួលនូវចំណេះដឹងជាច្រើន ហើយនាពេលបច្ចុប្បន្ន វិស័យមូលបត្រមានការប្រកួតប្រជែង និងជួញដូរយ៉ាងខ្លាំងនៅលើទីផ្សារ ទើបតម្រូវឱ្យមានការផ្សព្វផ្សាយយ៉ាងសកម្ម ពីសំណាក់ក្រុមហ៊ុនជាច្រើននៅលើពិភពលោក។ ក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងនោះ តែងតែរកវិធីសាស្ត្រដើម្បីធ្វើយ៉ាងណាឱ្យការបោះផ្សាយរបស់ខ្លួនទទួលបានប្រាក់ចំណូល និងអាចទទួលបានអតិថិជនគាំទ្រច្រើននៅលើវិស័យទីផ្សារមូលបត្រនេះ។

ការធ្វើទីផ្សារ គឺជាដំណើរការនៃការរៀបចំផែនការ អនុវត្តន៍ទ្រឹស្តី ការកំណត់ថ្លៃ ការបោះផ្សាយ និងការជួញដូរមូលបត្រ ដើម្បីបង្កើនការលក់ដែលតម្រូវទៅតាមគោលបំណងរបស់អតិថិជន និងសម្រេចគោលដៅរបស់ក្រុមហ៊ុន។ ដោយក្រុមរបស់យើងខ្ញុំយល់ឃើញថា ទីផ្សារមូលបត្រមានសារៈសំខាន់ខ្លាំងស្របពេលជាមួយនឹងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ទើបក្រុមយើងខ្ញុំ សម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលស្តីពី“**ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**” ដោយធ្វើការស្រាវជ្រាវក្នុងគោលបំណង ស្វែងយល់ពីដំណើរការបោះផ្សាយមូលបត្រនៅក្នុងប្រទេសកម្ពុជាយើង និងដើម្បីបង្ហាញពីអត្ថប្រយោជន៍ផ្សេងៗទៀត។ សម្រាប់ការស្រាវជ្រាវសារណារបស់ក្រុមយើងខ្ញុំ យើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសខុសឆ្គងទាំងពាក្យពេចន៍ អក្ខរាវិរុទ្ធ និងខ្លឹមសាររបស់ក្រុមយើងខ្ញុំដែលបានកើតឡើង ដោយអចេតនា។ យើងខ្ញុំដឹងថា កិច្ចការសារណានេះនៅមិនទាន់គ្រប់ជ្រុងជ្រោយ ដើម្បីបំពេញតម្រូវការរបស់និស្សិតនៅឡើយទេ ប៉ុន្តែក្រុមយើងខ្ញុំសង្ឃឹមថា ការស្រាវជ្រាវនិងចងក្រងសៀវភៅមួយក្បាលនេះ នឹងក្លាយជាសហការីដ៏ល្អរបស់និស្សិតសម្រាប់វិភាគ ដើម្បីទទួលជោគជ័យក្នុងការសិក្សា ដូច្នេះហើយ ទើបក្រុមយើងខ្ញុំខិតខំប្រឹងប្រែងស្រាវជ្រាវ និងចងក្រងនូវកិច្ចការនេះ។

ទន្ទឹមនឹងនេះ ក្រុមយើងខ្ញុំរង់ចាំនូវមតិរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ រៀមច្បង មិត្តរួមជំនាន់ និងសិស្សប្អូននិស្សិត ដើម្បីកែសម្រួលសៀវភៅនេះ ឱ្យកាន់តែមានភាពល្អប្រសើរថែមទៀត។

# រចនាសម្ព័ន្ធក្រុម



**ម៉ាប់ ម៉ីម៉ី**
ID: B21/2178



**ថៃ វណ្ណា**
ID: B21/1061



**ម៉យ ខាន់កែវ**
ID: B21/2192



**ជុំ ពៅសុធា**
ID: B21/3131



**ខុន សុខហេង**
ID: B21/781

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យនៃ វិទ្យាស្ថានវ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

លោកឪពុក អ្នកម្តាយដែលបានផ្តល់កំណើត ហើយខិតខំចិញ្ចឹមបីបាច់ថែរក្សាកូន ផ្តល់ដំបូន្មាន ព្រមទាំងបានឧបត្ថម្ភគាំទ្រ ទាំងសម្ភារ សព្វបែបយ៉ាងដល់កូន លើកទឹកចិត្តកូនតាំងពីចូលរៀនដំបូង រហូតដល់មានថ្ងៃនេះ ជាពិសេសបានបង្រៀនកូនឱ្យចេះស្រលាញ់និងស្នេហាជាតិមាតុភូមិកម្ពុជាទៀតផង។

ក្រុមនាងខ្ញុំ សូមសម្តែងនូវការគោរពយ៉ាងជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថានវ៉ាន់ដា ដែលបានផ្តល់កន្លែងបណ្តុះបណ្តាល បទពិសោធន៍ និងដំបូន្មានល្អៗ ហើយអនុគ្រោះដល់នាងខ្ញុំបានរៀន រហូតដល់ចប់ថ្នាក់បរិញ្ញាបត្រ និងទទួលបានជោគជ័យ។

ជាពិសេស សូមអរគុណដល់សាស្ត្រាចារ្យ **ម៉ូ ជុនហេង** ដែលបានដឹកនាំក្រុមនាងខ្ញុំ ដោយផ្តល់នូវវិធីសាស្ត្រផ្សេងៗ ក្នុងការស្រាវជ្រាវប្រមូលព័ត៌មាន សម្រាប់រៀបចំសរសេរសារណារបស់ក្រុមយើងខ្ញុំ ឱ្យរឹតតែមានភាពប្រសើរឡើង។

ជាទីបញ្ចប់ក្រុមនាងខ្ញុំទាំងអស់គ្នា សូមលើកដៃសំពះបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់អ្នកមានគុណខាងលើឱ្យជួបតែសេចក្តីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ក្រុមនាងខ្ញុំសូមគោរពដល់គុណូបការៈជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការដ៏មហាប្រសើរគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំសូមធានាអះអាង និងទទួលខុសត្រូវទៅលើខ្លឹមសារនៅក្នុងសារណានេះថា សារណានេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ក្រុមនាងខ្ញុំ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់ក្រុមអ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមាននៅក្នុងសារណានេះ គឺថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬរបាយការណ៍ណាមួយឡើយ។

ថ្ងៃ. .................. ខែ.......... ឆ្នាំ............. ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រដែលបានសិក្សារយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំជានិស្សិតដែលទទួលបាននូវការយកចិត្តទុកដាក់ ការជ្រោមជ្រែងយ៉ាងកក់ក្តៅពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យដែលប្រមូលផ្តុំទៅដោយអ្នកមានចំណេះដឹង។ ក្រុមនាងខ្ញុំបានចងក្រងសៀវភៅសារណា ដើម្បីបំពេញទៅតាមលក្ខខណ្ឌរបស់វិទ្យាស្ថាន វ៉ាន់ដាគណនេយ្យឱ្យបានត្រឹមត្រូវ ក្នុងគោលបំណងរៀបរៀង និងស្រាវជ្រាវពីប្រធានបទមួយស្តីពី "**ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**" ដើម្បីស្វែងយល់អំពីការវិភាគលើដំណើរការនៃការបោះផ្សាយមូលបត្ររបស់ក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា និងដើម្បីទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយយកទៅសិក្សាស្រាវជ្រាវបន្ថែមទៅលើប្រធានបទមួយនេះផងដែរ។

នៅក្នុងការបង្កើតក្រុមហ៊ុន ឬជួញដូរអ្វីមួយ គឺរមែងតែងតែចង់ទទួលបានជោគជ័យ និងការរកស៊ីមានដំណើរការឆ្ពោះទៅមុខយូរអង្វែង។ ដំណើរការបោះផ្សាយមូលបត្រមានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងការអភិវឌ្ឍក្រុមហ៊ុនឱ្យមានភាពរីកចម្រើន។ ដោយសំឡឹងឃើញពីសក្តានុពលដ៏ខ្លាំងនេះ គ.ម.ក បានរៀបចំជាព្រឹត្តិបត្រស្តីពី វិនិយោគិននិងការវិនិយោគ និងបោះពុម្ពផ្សាយដើម្បីចែកជូនដល់វិនិយោគិន សាធារណជន ក្រុមហ៊ុនមូលបត្រ គ្រឹះស្ថានអប់រំ ដៃគូរអភិវឌ្ឍន៍ និងស្ថាប័ននានា ក្នុងគោលដៅចូលរួមចំណែក ផ្តល់នូវចំណេះដឹង និងបទពិសោធន៍បន្ថែមទៀតពីវិស័យមូលបត្រ។ តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទនេះដោយផ្ទាល់ និងការសិក្សាស្រាវជ្រាវទៅលើឯកសាររបស់ក្រុមហ៊ុន ដែលធ្វើឱ្យក្រុមយើងទទួលបានផលសំខាន់ដូចជា៖ និយមន័យនៃដំណើរការបោះផ្សាយមូលបត្រ ការជួញដូរមូលបត្រ និងស្ថានភាពទូទៅរបស់ក្រុមហ៊ុន ប្រវត្តិក្រុមហ៊ុន ទស្សនវិស័យ ក៏ដូចជារចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ជាពិសេសផ្តោតទៅលើយុទ្ធសាស្ត្រក្នុងការជួញដូរ និងទីផ្សារគោលដៅ។ ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀតតាម និយមន័យច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជនសំដៅដល់ទីផ្សារឬទីកន្លែងជួញដូរ មូលបត្រឬប្រព័ន្ធដែលផ្តល់មធ្យោបាយងាយនៃការធ្វើសំណើរក្នុងការលក់ផ្ទេរ ឬការទិញ-លក់មូលបត្រ ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះរួមមានមូលបត្រកម្មសិទ្ធិមូលបត្របំណុល និងឧបករណ៍និទស្សន្នជាដើម។

ឆ្លងតាមការស្រាវជ្រាវកន្លងមកបានធ្វើឱ្យយើងឃើញនូវចំណុចល្អ និងចំណុចខ្វះខាតមួយចំនួនដែលត្រូវបំពេញបន្ថែមផងដែរ ហើយក៏សង្ឃឹមថាក្រុមហ៊ុននឹងកែសម្រួលនូវចំណុចខ្វះខាតមួយចំនួនដែលពាក់ព័ន្ធ ដែលអាចជួយឱ្យក្រុមហ៊ុនមានការអភិវឌ្ឍ និងរីកចម្រើនបន្ថែមទៀត។ ជាការពិតណាស់រាល់បម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ( សេដ្ឋកិច្ច-សង្គមនិងនយោបាយ )វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាម។ទីផ្សារមូលបត្រគឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិដែលគេតែងតែនិយាយថាទីផ្សារមូលបត្រ គឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ហេតុនេះស្ទើរ តែគ្រប់បណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍទាំងអស់មានទីផ្សារមូលបត្រនេះ។លើសពីនេះទៅទៀតមូលបត្រក៏ត្រូវបែងចែកជាពីរគឺ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលដែលត្រូវបានដាក់លក់នៅលើទីផ្សារមូលបត្រ។ ដូច្នេះនៅក្នុងក្រុមហ៊ុនសាជីវកម្មហិរញ្ញប្បទានកម្មសិទ្ធិ គឺសំដៅលើមូលបត្រកម្មសិទ្ធិរីឯហិរញ្ញប្បទានបំណុល គឺជាការសំដៅទៅលើមូលបត្របំណុល។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធក្រុម ........ ii
សេចក្ដីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v

## ជំពូកទី១ សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.តើដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ប្រព្រឹត្តទៅយ៉ាងដូចម្ដេច?
២.តើការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានផ្ដល់ប្រយោជន៍អ្វីខ្លះដល់ក្រុមហ៊ុនអ្នកវិនិយោគ និងសេដ្ឋកិច្ចជាតិ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំ និងដែនកំណត់ ........ ២
១.៤.២ វិសាលភាព ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៥.១ ការប្រមូលទិន្នន័យដំបូង ........ ២
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## ដំណើរការបោះផ្សាយមូលបត្រ

២.១ លក្ខណៈទូទៅនៃដំណើរការបោះផ្សាយ ........ ៤
២.១.១ និយមន័យនៃដំណើរការបោះផ្សាយ ........ ៤
២.១.២ ប្រវត្តិដំណើរការបោះផ្សាយមូលបត្រ ........ ៤
២.១.៣ មុខងារ និងតួនាទីរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយមូលបត្រ ........ ៥
២.២ ដំណើរការបោះផ្សាយមូលបត្រ ........ ៦
២.២.១ និយមន័យមូលបត្រ ........ ៦
២.២.២ ប្រវត្តិទីផ្សារមូលបត្រ ........ ៦
២.២.៣ ប្រភេទនៃមូលបត្រ ........ ៨

២.៣ លក្ខណសម្បត្តិនៃការបោះផ្សាយមូលបត្រ ដល់អ្នកវិនិយោគ និងសេដ្ឋកិច្ចជាតិ............. ៩
២.៣.១ និយមន័យលក្ខណសម្បត្តិ................................................................................ ៩
២.៣.២ លក្ខណសម្បត្តិនៃមូលបត្រ................................................................................ ៩
២.៣.៣ ផលប្រយោជន៍នៃមូលបត្រសម្រាប់អ្នកវិនិយោគ និងសេដ្ឋកិច្ច ............................១០

## ជំពូកទី៣

## ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

៣.១ ស្ថានភាពទូទៅនៃដំណើរការបោះផ្សាយមូលបត្រ..................................................១១
៣.១.១ ប្រវត្តិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ..........................................................១១
៣.១.២ អង្គភាពសំខាន់ៗរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ...........................................១៥
៣.១.៣ គោលនយោបាយរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្ររបស់ រ.ទ.ស.ភ.................... ១៧
ក. គោលនយោបាយ..................................................................................... ១៧
ខ.ទស្សនវិស័យ........................................................................................... ១៧
គ. បេសកកម្ម............................................................................................. ១៧
ឃ. ចក្ខុវិស័យ ............................................................................................. ១៧
ង.រចនាសម្ព័ន្ធ.............................................................................................១៩
៣.២ ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ..........................................២០
៣.២.១ ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ...........................២០
៣.២.២ ដំណើរការជួញដូរមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ .............................២៥
៣.៣ ផលប្រយោជន៍នៃការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ...........................៣១
៣.៣.១ ផលប្រយោជន៍ចំពោះក្រុមហ៊ុន ......................................................................... ៣១
៣.៣.២ ផលប្រយោជន៍ចំពោះអ្នកវិនិយោគ ....................................................................៣២
៣.៣.៣ ផលប្រយោជន៍ចំពោះសេដ្ឋកិច្ចជាតិ ..................................................................៣៣

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.................................................................................................... ៣៥
៤.២ ការវិភាគលើចំណុចខ្សោយ ................................................................................................. ៣៦

## ជំពូកទី៥

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ..............................................................................................................៣៧
៥.២ ការផ្តល់អនុសាសន៍ ..........................................................................................................៣៧
ឯកសារយោង
ឧបសម្ព័ន្ធ

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅ នៅក្នុងពិភពលោកតាមបណ្តាប្រទេសនីមួយៗដែលកំពុងអភិវឌ្ឍ ឬបានអភិវឌ្ឍរួចហើយ តែងតែរិះរកមធ្យោបាយឱ្យប្រទេសខ្លួនកាន់តែជឿនលឿន កាន់តែឈានទៅមុខ និងមានការរីកចំរើនឡើង ប្រទេសទាំងនោះត្រូវមានវិស័យនានានៅក្នុងដំណើរការសេដ្ឋកិច្ច ដែលនៅក្នុងវិស័យទាំងនោះក៏ត្រូវបាន បែងចែកជាច្រើនវិស័យនៅក្នុងប្រទេសនីមួយៗដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម វិស័យទេសចរណ៍ វិស័យអប់រំ វិស័យធនាគារ វិស័យសំណង់និងអចលនទ្រព្យ និងវិស័យហិរញ្ញវត្ថុ...។

នាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជាយើង ក៏មានវិស័យជាច្រើនដែលជាសរសៃឈាមសម្រាប់ជួយជំរុញឱ្យការអភិវឌ្ឍសេដ្ឋកិច្ចជាតិកាន់តែមានភាពរីកដុះដាល រីកចម្រើន ហើយនៅក្នុងវិស័យនោះ យើងកត់សម្គាល់ឃើញថាមានវិស័យមូលបត្រមួយ ដែលជាផ្នែកមួយនៃវិស័យហិរញ្ញវត្ថុ ដែលមានដំណើរការនៃការជួញដូរមកអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយមានក្រុមហ៊ុនធំៗមួយចំនួន មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យនេះ និងមានអ្នកចូលរួមវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់នៅលើទីផ្សារ និងបានធ្វើការចុះផ្សាយបោះលក់មូលបត្រព្រមទាំងអ្នកវិនិយោគិនមួយចំនួនទៀត ដែលបានជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាផងដែរ ហើយវិស័យមូលបត្រនេះ បានដើរតួយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមានការងារ ទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ ជាពិសេសបានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចប្រទេសជាតិថែមទៀតផង។ ចំណែកឯផ្សារមូលបត្រឬផ្សារហ៊ុននៅកម្ពុជា ក៏ជាកន្លែងជួញដូរភាគហ៊ុនឬជាកន្លែងដែលក្រុមហ៊ុនសារធារណៈ ឬស្ថាប័នរដ្ឋយកភាគហ៊ុនមកដាក់លក់ក្នុងផ្សារមូលបត្រដើម្បីឱ្យសាធារណជនចូលមកវិនិយោគឬទិញភាគហ៊ុន ហើយកំពុងមានការរីកដុះដាលនៅលើទីផ្សារដែលត្រូវបានទិញ និងលក់ដោយវិនិយោគិនផ្សេងៗគ្នា ទាំងជាតិ និងអន្តរជាតិ។

យ៉ាងណាមិញ វិស័យមូលបត្រនៅកម្ពុជាបានចូលរួមការអភិវឌ្ឍដើរតួជាមធ្យោបាយកៀរគរមូលធន និងការបែងចែកមូលធននៅកម្ពុជាឱ្យកាន់តែសម្បូរបែប សម្រាប់គម្រោងវិនិយោគនានា ដែលជាចំណុចសំខាន់នៅក្នុងសេដ្ឋកិច្ចក៏ប៉ុន្តែនៅមានសហគ្រាសតូចធំ និងប្រជាជនមួយចំនួនទៀតដែលមិនទាន់យល់ដឹងច្បាស់លាស់ចំពោះវិស័យមួយនេះ ថាការវិនិយោគលើវិស័យមូលបត្រនេះមានលក្ខណៈដូចម្តេចទេ។ ជាពិសេសគឺការយល់ដឹងពីការចាប់ផ្តើមដំណើរការនៃការបោះផ្សាយមូលបត្រ និងការជួញដូរមូលបត្រត្រូវចាប់ផ្តើមដោយរបៀបណានៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

អាស្រ័យហេតុនេះ ទើបបានជាយើងខ្ញុំជ្រើសរើសប្រធានបទដែលស្តីអំពី **“ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ”** មកសរសេរជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ក្នុងគោលបំណងជួយផ្តល់ជាចំណេះដឹងដល់សិស្សានុសិស្សនិងសាធារណជនមួយចំនួនដែលចង់យល់ច្បាស់ពីប្រធានបទមួយនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការជួញដូរមូលបត្រ បានដើរតួនាទីយ៉ាងសំខាន់សម្រាប់ក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលក្នុងការប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។

ហេតុដូច្នេះ ទើបក្រុមនាងខ្ញុំមានសំណួរសម្រាប់ចោទសួរនៅក្នុងប្រធានបទដូចខាងក្រោមនេះ៖

១. តើដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានការប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានផ្តល់ប្រយោជន៍អ្វីខ្លះដល់ក្រុមហ៊ុនអ្នកវិនិយោគ និងសេដ្ឋកិច្ចជាតិ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញអំពីដំណើរការនៃការបោះផ្សាយមូលបត្រនៅកម្ពុជាដោយផ្តោតទៅលើ ៖

- លក្ខណសម្បត្តិទូទៅស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រ
- យល់ដឹងពីផលប្រយោជន៍នៃការជួញដូរមូលបត្រ និងបោះផ្សាយចំពោះសេដ្ឋកិច្ច និងសង្គម
- ស្រាវជ្រាវទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃការបោះផ្សាយមូលបត្រ
- យល់ដឹងពីតួនាទី និងភារកិច្ច របស់អ្នកចូលរួម និងក្រុមហ៊ុនមូលបត្រ
- សិក្សាទៅលើគោលនយោបាយ ទស្សនវិស័យ ចក្ខុវិស័យ និងបេសកកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ទីផ្សារមូលបត្រមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសេដ្ឋកិច្ចជាតិ ដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់វិនិយោគិនក្នុងការវិនិយោគលើវិស័យមួយនេះ។ ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅក្រុមយើងខ្ញុំសូមលើកយកប្រធានបទមួយដែលទាក់ទងនឹង “**ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**” ដែលមានទីតាំងស្ថិតនៅស្នាក់ការ ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាព

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំផ្តោតសំខាន់ទៅលើដំណើរការបោះផ្សាយមូលបត្រ ការជួញដូរមូលបត្រ នៅឆ្នាំ២០២១។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវនេះ ប្រព្រឹត្តទៅយ៉ាងរលូន យើងខ្ញុំប្រើវិធីសាស្ត្រពីរយ៉ាងក្នុងការស្រាវជ្រាវគឺ៖

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

- សិក្សាស្រាវជ្រាវបន្ថែម ស្តាប់ការពន្យល់ណែនាំ និងការផ្តល់យោបល់ពីសាស្ត្រាចារ្យដឹកនាំ។

**១.៥.២ ការប្រមូលទិន្នន័យបន្ទាប់**

- ឯកសាររបស់រៀមច្បងជំនាន់មុនៗ
- គេហៈទំព័ររបស់ផ្សារមូលបត្រកម្ពុជា
- ឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ សេចក្តីប្រកាសនៅក្នុង គណៈកម្មការមូលបត្រកម្ពុជា។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

សារណាដែលបានសិក្សាស្រាវជ្រាវនេះនិងមានសារៈប្រយោជន៍ ចំពោះសង្គមជាតិ អ្នកវិនិយោគ និងនិស្សិតដែលមានគោលបំណងចង់ស្វែងយល់អំពីវិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជា ជាពិសេសសម្រាប់បុគ្គលដែលចង់វិនិយោគ ឱ្យកាន់តែយល់ច្បាស់ពីវិស័យមូលបត្រនិងផ្តល់ជាប្រយោជន៍ដូចជា ៖

- ជាឧបករណ៍មួយជួយដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។
- ជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា អាចពង្រីកអាជីវកម្មឱ្យរីកចម្រើនដោយប្រសិទ្ធភាព និងមានតម្លាភាព។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានចែកចេញជា ៥ជំពូកដែលមានលក្ខណៈដូចខាងក្រោម៖

- **ជំពូកទី១៖**ជំពូកនេះត្រូវបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្រ្តនៃការស្រាវជ្រាវ និងសារៈប្រយោជន៍នៃការស្រាវជ្រាវ។
- **ជំពូកទី២៖** ជំពូកនេះនិយាយអំពីទ្រឹស្តីដែលពាក់ព័ន្ធនឹងដំណើរការបោះផ្សាយមូលបត្រនៅកម្ពុជា ប្រវត្តិ និងជាតុផ្សំដែលទាក់ទងនៅក្នុងផ្សារមូលបត្រ។
- **ជំពូកទី៣៖** ជំពូកនេះនិយាយអំពីស្ថានភាពទូទៅ និងទីតាំងរបស់ រ.ទ.ស.ភ ទស្សនវិស័យ បេសកកម្ម គោលដៅ និងរចនាសម្ព័ន្ធរបស់ រ.ទ.ស.ភ។
- **ជំពូកទី៤៖** ជំពូកនេះនិយាយអំពីការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ ដែលវិភាគទៅលើគ្រប់ចំណុចទាំងអស់។
- **ជំពូកទី៥៖** ជំពូកនេះនិយាយពីសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ទៅលើគ្រប់ចំណុចទាំងអស់ បើមានខ្វះចន្លោះដើម្បីធ្វើការកែលំអ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ដំណើរការបោះផ្សាយមូលបត្រ

## ២.១ លក្ខណៈទូទៅនៃដំណើរការបោះផ្សាយ

### ២.១.១ និយមន័យនៃដំណើរការបោះផ្សាយ

ការបោះផ្សាយមូលបត្រ គឺជាការលក់ភាគហ៊ុនជាលើកដំបូងដោយក្រុមហ៊ុនឯកជនទៅកាន់សាធារណៈ។ នៅក្នុងដំណើរការបោះផ្សាយ ក្រុមហ៊ុនបោះផ្សាយទទួលជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ដែលជួយក្រុមហ៊ុនកំណត់ពីប្រភេទមូលបត្រ ដែលត្រូវបោះផ្សាយលក់ ហើយតម្លៃសម្រាប់ការលក់ គឺល្អបំផុតជាមួយពេលវេលាដែលត្រូវដាក់លក់ ឬឡើងនៅលើទីផ្សារ[1]។

ការបោះផ្សាយមូលបត្រ គឺជាការបោះផ្សាយលក់កម្មសិទ្ធិលើកដំបូងជាសាធារណៈដែលសំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវនៅមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត[2]។

### ២.១.២ ប្រវត្តិដំណើរការបោះផ្សាយមូលបត្រ

វិស័យមូលបត្រ គឺជាផ្នែកមួយយ៉ាងសំខាន់បំផុតនៅក្នុងប្រព័ន្ធទីផ្សារហិរញ្ញវត្ថុជាតិ ហើយវិស័យមូលបត្រនេះមានការបោះលក់ជាលើកដំបូងគេបង្អស់នៅដើមសតវត្សន៍ទី១៧ ក្នុងគ្រិស្តសករាជ១៦០២។ ប្រវត្តិនៃការកកើតទីផ្សារភាគហ៊ុនគឺមានការចាប់កំណើតឡើងដំបូងនៅលើទឹកដីអឺរ៉ុប ទីក្រុងអាំស្ទែដាំ សាធារណរដ្ឋហូឡង់ ហើយបានរីករាលដាលទៅដល់ប្រទេស ព័រទុយហ្គាល់ អេស្ប៉ាញ់ បារាំង ចក្រភពអង់គ្លេស។

ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍ ប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធនការវិនិយោគ និង ការវិភាជជាថ្មីនូវមូលធនតាមរយៈយន្តការទីផ្សារមូលបត្រ នៅខែ វិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់គ្នានេះ សម្តេចអគ្គសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឱ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជានៅ ខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀងធ្វើជាក្រុមហ៊ុនចំរុះគ្នា( Joint Venture)ដើម្បីបង្កើតផ្សារមូលបត្រ ("ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា") ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ( Joint Venture)ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន៥៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់ភាគហ៊ុន៤៥%នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបាន

---
[1] https://www.csx.com.kh
[2] https://www.csx.com.kh

ទទួលមូលបត្រអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រព្រម ទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក) ស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

ក្រោមដំណើរការជាច្រើនដំណាក់កាលកន្លងមកនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ គឺជាថ្ងៃប្រវត្តិដ៏សំខាន់មួយនៃវិស័យហិរញ្ញវត្ថុ និងជាមោទនភាពមួយសម្រាប់ប្រទេសកម្ពុជា ដែលនៅទីបំផុតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(Cambodia Securities Exchange) បានឈានដល់ដំណាក់កាលចុងក្រោយ ដែលនឹងត្រូវបានដាក់សម្ពោធឱ្យមានដំណើរការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាគណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក)។ ទន្ទឹមនឹងនោះផងដែរ ខែមករា ឆ្នាំ២០១២ ឯកឧត្តម **ហ៊ាន សាហ៊ីប** ប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជាបានបញ្ជាក់ពីស្នាដៃ និងលទ្ធផលកន្លងមក ក៏ដូចជាបង្ហាញពីភាពត្រៀមខ្លួនជាស្រេចសម្រាប់ដំណើរការបោះផ្សាយមូលបត្រមួយនេះនៅកម្ពុជា។ ជាក់ស្តែងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីផ្សារទាំងផ្នែករឹង ទាំងផ្នែកទន់ត្រូវបានសម្រេចដោយជោគជ័យទាំងស្រុង ជាពិសេសនោះគឺទីផ្សារ(ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា) និងអន្តរការីទីផ្សារ(ក្រុមហ៊ុនមូលបត្រ)។ ប៉ុន្តែ នៅមានភាពយឺតយ៉ាវមួយចំនួន ពោលគឺផលិតផល(ក្រុមហ៊ុនចុះបញ្ជី) កំពុងស្ថិតក្នុងដំណាក់កាលនៃការរៀបចំ ការបោះផ្សាយមូលបត្រលើកដំបូង(IPO)របស់ខ្លួន។ ជាលទ្ធផលចុងក្រោយបង្អស់នៃការងារ ការខិតខំប្រឹងប្រែងកន្លងមកនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង៩:០៩នាទី ព្រឹក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានអនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិជាលើកដំបូង ដែលត្រូវបានប្រកាសបើកជាផ្លូវការ តាមរយៈសារវីដេអូដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងមានវត្តមានតំណាងឱ្យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**[3]។

### ២.១.៣ មុខងារ និងតួនាទីរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយមូលបត្រ

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយមូលបត្រមាន មុខងារ និងតួនាទីដូចតទៅ ៖

- រៀបចំលក្ខខណ្ឌតម្រូវការនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុននានា បោះផ្សាយលក់មូលបត្រជាសាធារណៈ។
- រៀបចំលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ត្រួតពិនិត្យលក្ខខណ្ឌនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ។
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ត្រួតពិនិត្យ និងងផ្តល់យោបល់លើការស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ។
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ។

[3] https://youtu.be/iiZns7_QUiE?si=Nzur-_VkS2sfW8Rq

- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានារបស់កក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានេជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិច ឬតាមប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈ។
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើ មានការចាំបាច់ស្រមតាមក្របខណ្ឌការងារ។
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើកាស៊ើបអង្កេតបន្ត[4]។

## ២.២ ដំណើរការបោះផ្សាយមូលបត្រ

### ២.២.១ និយមន័យមូលបត្រ

មូលបត្រ គឺតំណាងឱ្យម្ចាស់កម្មសិទ្ធ និងតំណាងឱ្យភាពជាម្ចាស់បំណុលរបស់ក្រុមហ៊ុន ឬរបស់អង្គភាពណាមួយតាមការកៀរគរមូលធនតាមរយៈទីផ្សារ[5]។

មូលបត្រ គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន ដែលកិច្ចសន្យានេះ បញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធ ឬ ម្ចាស់បំណុលលើក្រុមហ៊ុនមួយហើយយើងក៏អាចធ្វើការជួញដូរមូលបត្រនេះបានដែរ៕

មូលបត្រមាន៣ប្រភេទគឺ**ភាគហ៊ុន សញ្ញាប័ណ្ណ និង ឧបករណ៍និស្សន្ទ**[6]។

### ២.២.២ ប្រវត្តិទីផ្សារមូលបត្រ

យោងតាមឯកសារដកស្រង់ចេញពីគេហទំព័រ "Stock Exchange, Stock Market" ទីផ្សារភាគហ៊ុន (Stock Market) មានប្រវត្តិតាំងពីយូរណាស់មកហើយ។ បច្ចុប្បន្ននេះទីផ្សារត្រូវបានគេធ្វើបច្ចុប្បន្នកម្មទៅជាទីផ្សារមូលបត្រ (Securities Market) ។ទីផ្សារភាគហ៊ុនប្រើប្រាស់រយៈពេលរាប់សតវត្សក្នុងការវិវត្តរហូតក្លាយទៅជាទីផ្សារមូលបត្រដូចបច្ចុប្បន្ន។ ប៉ុន្តែប្រទេសជាច្រើននៅតែពេញនិយមក្នុងការប្រើប្រាស់ពាក្យ "ទីផ្សារភាគហ៊ុន" ជាជាង "ផ្សារមូលបត្រ" ដដែល។

ទីផ្សារភាគហ៊ុនកើតឡើងដំបូងប្រហែលជានៅពេលដែលភាគហ៊ុនរបស់ The Dutch East India Company ត្រូវបានជួញដូរនៅលើទៅផ្សារ អាំស្តែដាំ (Amsterdam Market) ។ ក្រុមហ៊ុន The Dutch East India Company បង្កើតនៅឆ្នាំ ១៦០២ ហើយវាជាក្រុមហ៊ុន ដំបូងគេដែលបោះផ្សាយលក់ភាគហ៊ុនដើម្បីប្រមូលទុនសម្រាប់ការវិនិយោគរបស់ខ្លួន។ ភាគរយនៃផលចំណេញរបស់ក្រុមហ៊ុនត្រូវបានផ្តល់ជូនដល់អ្នក

[4] *វិស័យមូលបត្រនៅកម្ពុជា* Page 12

[5] https://youtu.be/iiZns7_QUiE?si=Nzur-_VkS2sfW8Rq

[6] https://www.linkedin.com/pulse

ទិញដោយអាស្រ័យទៅនឹងភាគហ៊ុនដែលមាន។ ភាគហ៊ុននេះត្រូវបានគេជួញដូរជាបន្តបន្ទាប់រហូតលេចចេញការជួញដូរលើ ក្រុមហ៊ុនផ្សារអាំស្ទែដាំ(Amsterdam Exchange) ។ ហើយក្រោយមក ឧបករណ៍ហិរញ្ញវត្ថុសម្បូរបែបផ្សេងៗត្រូវបានធ្វើការទិញ-លក់ ទៅផ្សារអាំស្ទែដាំ( Amsterdam Market )នេះ។ ក្រុមហ៊ុនផ្សារភាគហ៊ុន Stock Exchange នៅក្រុងញូវយ៉កត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៧៩២ នៅពេលដែលឈ្មួញជើងសារ(Brokers) ចំនួន២៤នាក់ បានសម្រេចចិត្តយកកម្រៃជើងសារនៅពេលដែលពួកគេដើរតួជាភ្នាក់ងារសម្រាប់មនុស្សផ្សេងៗទៀតក្នុងការធ្វើជំនួញ។ ពួកគេបានធ្វើការជួញដូរជាច្រើននៅក្រោមដើមឈើមួយនៅវ៉លស្ទ្រីត( Wall Street ) ជាប្រចាំទើបបង្កើតឱ្យមានទីផ្សារមួយឈ្មោះថា វ៉លស្ទ្រីត( Wall Street) មកដល់បច្ចុប្បន្ននេះនៅសហរដ្ឋអាមេរិក។

ឧបករណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល បានបង្កើតនូវមូលដ្ឋានគ្រឹះនៃការធ្វើការជួញដូរជាលើកដំបូង ហើយភាគហ៊ុនរបស់ធនាគារ និងក្រុមហ៊ុនធានារ៉ាប់រងបានបន្ថែមលើបរិមាណនៃការប្រតិបត្តិការនៃការជួញដូរបន្ថែមទៀត។ ក្នុងឆ្នាំ១៨១៧ ឈ្មួញជើងសារ នៅទីក្រុងញូវយ៉កបានសម្រេចចិត្តចាត់ចែងជាផ្លូវការនូវក្រុមប្រឹក្សាសម្រាប់ទីផ្សារភាគហ៊ុន បន្ទាប់មកទីផ្សារភាគហ៊ុនបានរីកចម្រើនជាមួយនឹងឧស្សាហូបនីយកម្មរបស់អាមេរិកដែរ។ នៅឆ្នាំ១៨៦៣ ក្រុមហ៊ុនផ្សារភាគហ៊ុននៅទីក្រុងញូវយ៉ក បានអនុម័តនូវឈ្មោះបច្ចុប្បន្នរបស់ខ្លួនគឺ ក្រុមហ៊ុនផ្សារភាគហ៊ុនញូវយ៉ក( New York Stock Exchange ) ។ក្នុងពេលនៃសង្គ្រាមស៊ីវិលក្រុមហ៊ុនផ្សារភាគហ៊ុនមួយចំនួនបន្ថែមទៀតត្រូវបានគេបង្កើតឡើង ហើយក្រុមហ៊ុនផ្សារភាគហ៊ុនមួយក្នុងចំណោមផ្សារភាគហ៊ុនទាំងនោះ ដែលចាត់ទុកជាអ្នកនាំមុខគេគឺ ក្រុមហ៊ុនផ្សារអាមេរិក( American Stock Exchange ) គឺជាក្រុមហ៊ុនផ្សារភាគហ៊ុនធំទី២នៅសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ននេះ។

ផ្សារភាគហ៊ុនមានការវិវត្តខ្លាំងក្រោយសង្គ្រាមលោកលើកទី២។ សង្គ្រាមលោកលើកទី២បានជះឥទ្ធិពលជាវិជ្ជមានជាច្រើនដល់ការវិវត្តរបស់ទីផ្សារនេះ ព្រោះក្រោយពីប្រទេសទាំងអស់ងើបពីសង្គ្រាមហិរញ្ញប្បទានជាបញ្ហាប្រឈមមួយដ៏ធ្ងន់ធ្ងរ។ រដ្ឋាភិបាលនៃប្រទេសមួយចំនួនមានការចាប់អារម្មណ៍ក្នុងការប្រើប្រាស់ទីផ្សារភាគហ៊ុន ព្រោះការវិវត្តខាងផ្នែកនយោបាយក្រោយសង្គ្រាមបានធ្វើឱ្យរដ្ឋាភិបាលខំស្វែងរកនូវប្រភពទុនថ្មីៗសម្រាប់ទ្រទ្រង់ការចំណាយចរន្ត នឹងចំណាយមូលធនរបស់ខ្លួនហើយទីផ្សារភាគហ៊ុនជាជម្រើសប្រភពហិរញ្ញប្បទានដ៏ល្អមួយ។ម្យ៉ាងទៀតដើម្បីធ្វើឱ្យសាច់ប្រាក់មានចលនាវិលឡើងចុះកាន់តែខ្លាំងនៅក្នុងចរន្តសេដ្ឋកិច្ច ក៏ដូចជាធ្វើឱ្យសកម្មភាពនៃជំនួញកាន់តែមានភាពរស់រវើកថែមទៀត ក្នុងទិសដៅលើកកម្ពស់សេដ្ឋកិច្ចដែលទើបងើបពីសង្គ្រាមទីផ្សារភាគហ៊ុន ក៏ជាគោលនយោបាយមួយដ៏ល្អសម្រាប់រដ្ឋាភិបាលផងដែរ។ ធនាគារក្រុមហ៊ុនធានារ៉ាប់រង និងសហគ្រាសរួមទុនមួយចំនួនទៀតជាពិសេសក្រុមហ៊ុនពាណិជ្ជកម្មធំៗ ក៏ខ្វះប្រភពទុនថ្មីៗ ដែលសម្រាប់យកមកទ្រទ្រង់ការចំណាយ នឹងការពង្រីកនូវមុខជំនួញរបស់គេជាហេតុធ្វើឱ្យទីផ្សារភាគហ៊ុនជាជម្រើសប្រភពហិរញ្ញប្បទានដ៏ល្អមួយរបស់ពួកគេបន្ថែមលើប្រភពហិរញ្ញប្បទានផ្ទាល់ខ្លួន និងហិរញ្ញប្បទានដោយប្រយោលតាមរយៈធនាគារ។ ភាពរួមគ្នានៃតម្រូវការទាំងនេះទីផ្សារភាគហ៊ុនកាន់តែច្រើនត្រូវបានគេបង្កើត ដើម្បីធ្វើសញ្ជ័យលើធនធាន នឹងកៀរគរនូវធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗ។ ការធ្វើសញ្ជ័យលើធនធាន នឹងកៀរគរនូវធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗទាំងនេះធ្វើឡើងតាមរយៈការបោះផ្សាយលក់ឧបករណ៍ហិរញ្ញវត្ថុដោយផ្តល់ផលប្រយោជន៍ហិរញ្ញវត្ថុនឹងមិនមែនហិរញ្ញវត្ថុដល់អ្នកលក់ អ្នកទិញ ហើយនឹងអ្នកទិញហើយលក់វិញផងដែរ។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានគេជួញដូរនៅលើទីផ្សារភាគហ៊ុនជា

បន្តបន្ទាប់។ តាំងពីពេលនោះមកមានប្រទេសជាច្រើនផ្សេងៗទៀតបានមើលឃើញពីអត្ថប្រយោជន៍ពីទីផ្សារភាគហ៊ុននៅបណ្ដាប្រទេសទាំងនោះបានចាប់ផ្ដើមខិតខំបង្កើតជាទីផ្សារនេះឡើងផងដែរ។

ទីផ្សារភាគហ៊ុនបានអភិវឌ្ឍយ៉ាងលឿនដែលមានឧបករណ៍ហិរញ្ញវត្ថុជាច្រើនដូចជាសញ្ញាណបណ្ណ ឧបករណ៍ដេរីវេទីវ ឬឧបករណ៍និស្សន្ទ ត្រូវបានគេទិញ-លក់នៅលើទីផ្សារនេះផងដែរ ពុំមែនមានតែភាគហ៊ុនប៉ុណ្ណោះទេ។ ហេតុដូចនេះអ្នកវិនិយោគសាធារណរដ្ឋងាយនឹងយល់ច្រឡំអំពីទីផ្សារនេះណាស់ នៅពេលប្រើប្រាស់ពាក្យទីផ្សារភាគហ៊ុន ព្រោះពួកគេអាចយល់បានថាភាគហ៊ុនជាឧបករណ៍តែមួយគត់ដែលត្រូវបានគេទិញលក់នៅលើទីផ្សារនេះ។ ក្រោយមកឧបករណ៍ទាំងអស់ដែលគេទិញ-លក់ត្រូវបានគេហៅថាមូលបត្រ ជំនួសវិញហើយទីផ្សារដែលជាកន្លែងទិញ-លក់មូលបត្រនេះជាទីផ្សារមូលបត្រ។

ធ្វើឡើងដោយអ្នកស្រាវជ្រាវអាឡឺម៉ង់ដែលយល់ថាការមិនយល់ស្របរបស់វិនិយោគិននាំឱ្យមានការកើនឡើងទៅលើពាណិជ្ជកម្ម។ ប៉ុន្តែការសង្កេតលើបរិមាណជួញដូរមិនធម្មតាមិនចាំបាច់បង្ហាញពីការខ្វែងគំនិតគ្នាទេហើយបរិមាណមានការកើនឡើង ទោះបីជាវិនិយោគិនបកស្រាយព័ត៌មានដោយអត្តសញ្ញាណក៏ដោយប្រសិនបើពួកគេមានការរំពឹងទុកខុសគ្នាដែរ។ ការធ្វើត្រាប់តាមការពិសោធគាំទ្រដល់គំរូហើយត្រូវបានប្រើដើម្បីប្រៀបធៀបបរិយាកាសផ្ទុះផ្ដង់ដោយចៃដន្យជាមួយការទូទាត់ទីផ្សារដែលមិនថ្លៃ។ បរិមាណគឺទាបជាង នៅក្នុងទីផ្សារថ្លៃហើយបរិមាណកើនឡើងបណ្ដាមកពីព្រឹត្តិការណ៍ព័ត៌មាននៅតែបន្តបន្ទាប់ពីព្រឹត្តិការណ៍នេះ។ ស្របទៅតាមភស្តុតាងដែលមានស្រាប់ និងបង្ហាញថាទីផ្សារមិនត្រូវបានបញ្ជាទិញភ្លាមៗ ឬវិនិយោគិនមានការទាមទារដើម្បីដកហូតបានមកវិញទេ។

**២.២.៣ ប្រភេទនៃមូលបត្រ**

**ក.មូលបត្របំណុល (Bond)**

សព្វថ្ងៃភាគហ៊ុនទីផ្សារនៅកម្ពុជា កំពុងទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជាជាច្រើន។ ការវិនិយោគទៅលើមូលបត្របំណុល ឬ សញ្ញាបណ្ណក៏ជាផ្នែកមួយដែលលអាចកៀងគរប្រមូលនូវដើមទុនដើម្បីពង្រីកអាជីវកម្មផងដែរ។

បើយោងតាមការចុះផ្សាយរបស់គេហទំព័ររបស់ **ផ្សារមូលបត្រកម្ពុជា** បានរៀបរាប់ថា មូលបត្រឬបណ្ណបំណុល គឺជាកិច្ចសន្យាខ្ចីប្រាក់រវាងអ្នកបោះផ្សាយមូលបត្រ និងវិនិយោគិន។ បុគ្គលដែលបោះផ្សាយសញ្ញាបណ្ណត្រូវបង់ជាការប្រាក់ឱ្យទៅវិនិយោគិនតាមពេលវេលាជាក់លាក់ និងទៀងទាត់ ព្រមទាំងត្រូវសងថ្លៃដើមដែលបានខ្ចីវិនិយោគិនតាមកាលកំណត់ដែលត្រូវសង។ សញ្ញាបណ្ណរួមមាន **សញ្ញាបណ្ណសាជីវកម្ម** និង**សញ្ញាបណ្ណសហគ្រាស** ឬ **រាជរដ្ឋាភិបាល**។ សញ្ញាបណ្ណ តំណាងឱ្យភាពជាម្ចាស់បំណុល។ សញ្ញាបណ្ណធ្វើការទូទាត់តែការប្រាក់ដែលបានកំណត់ជាមុនប៉ុណ្ណោះ ហើយថ្លៃរបស់វាប្រែប្រួលនៅក្នុងដែនកំណត់ដោយអត្រាការប្រាក់ ពោលគឺមិនមែនកំណត់ដោយប្រាក់ចំណេញរបស់ក្រុមហ៊ុននោះឡើយ។

**ខ.មូលបត្រកម្មសិទ្ធិ (Stock)**

មូលបត្រកម្មសិទ្ធិគឺ ជាមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាធារណៈដើម្បីកៀងគរមូលនិធិពីសាធារណជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឱ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ និងផ្ដល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិក គឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួលនូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្មរបស់

ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបានតាមរយៈភាគលាភដែលភាគហ៊ុនិកបានទទួល និងតាមរយៈតម្លៃភាគហ៊ុនដែលបានដាក់ថ្លៃនៅលើទីផ្សារ។

ជារួមមក មូលបត្រកម្មសិទ្ធិសំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃការចូលរួម រួមទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោតភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។ មូលបត្រកម្មសិទ្ធិចែកចេញជាពីរប្រភេទ៖

• ភាគហ៊ុនធម្មតាៈ ផ្តល់ឱ្យភាគហ៊ុននូវសិទ្ធិបោះឆ្នោតប៉ុន្តែមិនធានាលើភាគលាភ។ ភាគហ៊ុនធម្មតាគឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលភាគហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។

• ភាគហ៊ុនបុរិមាៈ មិនមានសិទ្ធិបោះឆ្នោត ប៉ុន្តែទទួលបានភាគលាភមុន។ ភាគហ៊ុនបុរិមា ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។

ភាពខុសគ្នារវាងភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា គឺអ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា[7]។

## ២.៣ លក្ខណសម្បត្តិនៃការបោះផ្សាយមូលបត្រ ដល់អ្នកវិនិយោគ និងសេដ្ឋកិច្ចជាតិ

### ២.៣.១ និយមន័យលក្ខណសម្បត្តិ

លក្ខណសម្បត្តិ មានមានន័យថាលក្ខណៈដែលត្រូវបំពេញខានពុំបាន[8]។

លក្ខណសម្បត្តិ លក្ខណៈសម្បត្តិគឺជាការគ្រប់គ្រងដោយលក្ខណៈ[9]។

### ២.៣.២ លក្ខណសម្បត្តិនៃមូលបត្រ

មូលបត្រ គឺជាប័ណ្ណភាគហ៊ុនមួយដែលជួយសម្រួលដល់ម្ចាស់អង្គភាព អាជីវកម្ម សហគ្រាសនានាក្នុងការពង្រីកអាជីវកម្ម ការរកស៊ី ឱ្យកាន់តែ ឬការខ្ចីប្រាក់រវាងអ្នកដាក់លាក់ ឬអ្នកជាសាធារណៈ។ ជាពិសេសជួយក្នុងការផ្តល់ហិរញ្ញប្បទានរយៈពេលមធ្យម រយៈពេលវែងដល់ក្រុមហ៊ុនសហគ្រាសក្នុងការពង្រីកអាជីវកម្ម ឬក្នុងការបង្កើតការប្រកួតប្រជែងផ្សេងៗ។ ជាធម្មតានៅពេលក្រុមហ៊ុនចង់បង្កើតដើមទុនតាមរយៈការបង្កើតអាជីវកម្មគេតែងតែស្វែងរកហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រ យើងឃើញមូលហេតុដែលគេស្វែងរកហិរញ្ញប្បទានតាមទីផ្សារមូលបត្រ គឺធ្វើឱ្យក្រុមហ៊ុនអាចកៀងគរមូលធននូវចំនួនច្រើន ធ្វើឱ្យគេអាចស្វែងរកហិរញ្ញប្បទានរយៈពេលយូរ ពិសេសជាងនេះទៀតធ្វើឱ្យក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះកាន់តែល្អតាមរយៈការបោះផ្សាយលក់មូលបត្រ។

### ២.៣.៣ ផលប្រយោជន៍នៃមូលបត្រសម្រាប់អ្នកវិនិយោគ និងសេដ្ឋកិច្ច

➢ ការជួញដូរមូលបត្រនៅកម្ពុជា បានផ្តល់ផលប្រយោជន៍ដល់អ្នកវិនិយោគ

ជម្រើសនៃការវិនិយោគដើម្បីទទួលបានអត្ថប្រយោជន៍ពីវិស័យមូលបត្រ ទីផ្សារកំពុងផ្តល់ជម្រើសវិនិយោគគួរឱ្យចាប់អារម្មណ៍។ អ្នកវិនិយោគអាចវិនិយោគក្នុងទីផ្សារមូលបត្រដោយប្រើឧបករណ៍ហិរញ្ញវត្ថុដូចជាមូលបត្រ។ ការវិនិយោគលើមូលបត្រ នឹងនាំមកនូវអត្ថប្រយោជន៍ដូចជា ភាគលាភ ប្រាក់ចំណេញ

[7] economy.ams.com.kh
[8] https://buykhmerbook.com/archives/130936
[9] *ដកស្រង់ចេញពីវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត (1967 p.1088)*

ដើមទុន ដើម្បីទទួលបានប្រាក់ចំណេញពីការវិនិយោគរបស់ពួកគេ អ្នកវិនិយោគគួរតែប្រាកដថាពួកគេវិនិយោគនៅពេលត្រឹមត្រូវ និងសម្រាប់ហេតុផលត្រឹមត្រូវ។ នេះមានន័យថាពួកគេទិញ ឬលក់មូលបត្ររបស់ពួកគេដោយផ្អែកលើការពិចារណាដ៏រឹងមាំ និងដោយហេតុផលសមស្រប ហើយមិនមែនដោយសារតែអារម្មណ៍ ឬប្រតិកម្មហួសហេតុពីព័ត៌មានអវិជ្ជមានលើក្រុមហ៊ុន ឬសេដ្ឋកិច្ចនោះទេ។ ហើយវាក៏បានបង្រៀនអ្នកឱ្យបានស្គាល់ពីការរកស៊ីវិនិយោគនិងប្រភេទនៃមនុស្សក្នុងសង្គមដែរ។ ទោះបីអ្នកប្រឈមមុខនឹងការលំបាកមួយចំនួនក្នុងការវិនិយោគដំបូងក្នុងជីវិត ដោយសារអ្នកវិនិយោគមិនមានលុយគ្រប់គ្រាន់ ប៉ុន្តែវាជាបទពិសោធន៍មួយទៅរកភាពជោគជ័យ ។ ក្នុងអំឡុងពេលបែបនេះ ការវិនិយោគដែលបានធ្វើឡើងនឹងអាចបង្ហាញថាមានប្រយោជន៍ខ្លាំងណាស់ ហើយនឹងជួយអ្នកឱ្យឆ្លងកាត់ពេលវេលាដ៏លំបាកដោយអ្នកវិនិយោគផ្ទាល់។ ហើយមានចំណុចមួយចំនួនដែលគួរពិចារណានៅពេលវិនិយោគលើមូលបត្រ រួមទាំងតម្លៃមូលបត្រ និងស្ថានភាពរបស់ក្រុមហ៊ុន ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចក្នុងស្រុក និងអន្តរជាតិ៕

➢ ការជួញដូរមូលបត្រនៅកម្ពុជា បានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច

យើងឃើញថាជាធម្មតានៅប្រទេសនានាមានសេដ្ឋកិច្ចរីកចម្រើនដោយសារតែទីផ្សារមូលបត្រដើរតួនាទីសំខាន់ចំពោះសេដ្ឋកិច្ច។ ដូច្នេះដើម្បីឱ្យសេដ្ឋកិច្ចរីកចម្រើនយើងត្រូវមានទីផ្សារមូលបត្របានជាយើងត្រូវមានទីផ្សារមូលបត្រ ព្រោះទីផ្សារមូលបត្រគឺជាកត្តាលិករមួយដែលជំរុញឱ្យសេដ្ឋកិច្ចមានការីកចម្រើនឱ្យកាន់តែឆាប់រហ័ស យើងឃើញថានៅពេលដែលមានទីផ្សារមូលបត្រគឺបានធ្វើឱ្យសាធារណជន ពួកគេមានជំរើសក្នុងការវិនិយោគមួយថែមទៀតនៅក្នុងអាជីវកម្មរបស់ពួកគេ ឬក៏ជួយលើកទឹកចិត្តដល់សាធារណជនធ្វើការសន្សំ និងធ្វើការកៀងគរលុយដែលនៅទំនេរអត់ប្រើប្រាស់យកទៅធ្វើការវិនិយោគតាមរយៈទៅដាក់សន្សំនៅធនាគារណាមួយ ហើយទីផ្សារមូលបត្រគឺជាមធ្យោបាយមួយក្នុងការកៀងគរមូលធននៅពេលក្រុមហ៊ុនណាមួយរកស៊ីហើយខ្វះនូវហិរញ្ញប្បទាន ពួកគាត់អាចស្វែងរកហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រដោយធ្វើការបោះផ្សាយមូលបត្រតាមចិត្តដើម្បីយកមូលធនមកធ្វើការវិនិយោគជំរុញឱ្យសេដ្ឋកិច្ចមានការរីកចម្រើនហើយបង្កើតឱ្យមានការងារធ្វើនៅក្នុងស្រុក[10]។

[10] https://buykhmerbook.com/archives/130936

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ៣.១ ស្ថានភាពទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.១.១ ប្រវត្តិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ១៩៥៩ និងមានការតែងតាំងជាផ្លូវការតាមរយៈព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរៈក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ១៦៤នសចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៦០ ជាអង្គភាពផលិតកម្មនិងអាជីវកម្មរបស់រដ្ឋចំណុះដោយផ្ទាល់នៃសាលាក្រុងភ្នំពេញហើយត្រូវបានដាក់ប្រសិទ្ធនាមជាផ្លូវការថា«រដ្ឋាករទឹកភ្នំពេញ»។ អង្គភាពនេះមានភារកិច្ចក្នុងការផលិតទឹកស្អាត និងបានផ្គត់ផ្គង់បម្រើរាល់តម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ ព្រមទាំងធានាឱ្យបាននូវតុល្យការចំណូល និងចំណាយលើការងារផលិតកម្ម និងវិនិយោគ។



នៅកំឡុងឆ្នាំ១៨៩៥ ប្រព័ន្ធផ្គត់ផ្គង់ទឹកសម្រាប់ទីក្រុងភ្នំពេញត្រូវបានរៀបចំឡើង ជាលើកដំបូងដោយក្រុមហ៊ុនទឹកនិងអគ្គិសនីឥណ្ឌូចិនរបស់បារាំងដែលមានឈ្មោះថា(CEEI) ត្រូវបានវិនិយោគទុនសាងសង់រោងចក្រផលិតទឹកស្អាតជ្រោយចង្វារ ដែលមានសមត្ថភាពផលិតទឹកស្អាតជាមធ្យម១៥,០០០ម$^3$/ថ្ងៃ ហើយព្រមទាំងបណ្តាញចែកចាយប្រវែង៤០គីឡូម៉ែត្រ ហើយស្ថិតនៅក្នុងខណ្ឌដូនពេញភាគខាងកើតនៃរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន។ នៅកំឡុងពេលនោះដែរ ការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងទីក្រុងភ្នំពេញត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មថវិកាចំណូលដើម្បីធានាដំណើរការផលិត និងវិនិយោគដោយខ្លួនឯងក្រោមលក្ខខន្តិកៈដោយឡែករបស់ក្រុមហ៊ុនឥណ្ឌូចិនបារាំង។

ចាប់តាំងពីឆ្នាំ១៩៥៧ រហូតដល់ឆ្នាំ១៩៧០ ការងារផ្គត់ផ្គង់ទឹកស្អាតរួមទាំងការធ្វើដំណើរការនៃអាជីវកម្មរបស់រដ្ឋាករទឹកស្អាតទីក្រុងភ្នំពេញ ត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀតទៅលើការជួសជុលបង្កើតរោងចក្រផលិតទឹកស្អាតនៅបណ្តាញចែកចាយថ្មីដូចមានរៀបរាប់ខាងក្រោម៖

១. ក្នុងឆ្នាំ ១៩៥៧ រោងចក្រចំការមនដែលមានសមត្ថភាពផលិត១០០០០ម$^3$/ថ្ងៃ ត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុនដឺក្រេម៉ុង( DEGREMONT )។

២. ក្នុងឆ្នាំ១៩៥៩រោងចក្រទឹកស្អាតជ្រោយចង្វារត្រូវបានជួសជុល និងពង្រីកនូវសមត្ថភាពក្នុងការផលិតបន្ថែមរហូតដល់៤៥០០០ម$^3$/ថ្ងៃ។

៣ . ក្នុងឆ្នាំ១៩៦៦រោងចក្រផលិតទឹកថ្មីមួយនៅភូមិព្រែកត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុនផលិតទឹកស្អាតពិចាបាល( PICCHABAL )ដែលមានសមត្ថភាពផលិត១០០០០០ម$^3$/ថ្ងៃ។

៤ . ប្រព័ន្ធបណ្តាញចែកចាយទឹកត្រូវបានជួសជុល និងពង្រីកបន្ថែម២៤២មនៅតាមបណ្តាឆ្នាំដូចខាងក្រោម៖

ក . ក្នុងឆ្នាំ១៩៥៧បណ្តាញមេ រួមទាំងបណ្តាញចែកចាយទឹកប្រវែង៣៦គីឡូម៉ែត្រត្រូវបានដាក់បន្ថែមដោយក្រុមហ៊ុនដឺក្រេម៉ុង( DEGREMONT )។

ខ. ក្នុងឆ្នាំ១៩៥៩បណ្តាញមេ រួមទាំងបណ្តាញចែកចាយទឹកប្រវែង៣២គីឡូម៉ែត្រត្រូវបានដាក់បន្ថែមដោយក្រុមហ៊ុនគូប៊ូតា( KUBUTA )។

គ. ក្នុងឆ្នាំ១៩៥៩បណ្តាញមេ រួមទាំងបណ្តាញចែកចាយទឹកប្រវែង១៦៥គីឡូម៉ែត្រត្រូវបានដាក់បន្ថែមដោយរដ្ឋាករទឹកភ្នំពេញ។ដោយសារមានសកម្មភាពការងារជួសជុល និងពង្រីកបន្ថែមអំពីប្រព័ន្ធផ្គត់ផ្គង់ខាងលើបានធ្វើឱ្យសមត្ថភាពផលិតទឹកស្អាតសរុបកើតឡើងដល់ ២៥០០០ម$^3$/ថ្ងៃ ក្នុងឆ្នាំ១៩៥៩ដល់៥៥០០០ម$^3$/ថ្ងៃក្នុងឆ្នាំ១៩៦៣និង១៥៥០០០ម$^3$/ថ្ងៃក្នុងឆ្នាំ១៩៦៦។ ការគ្រប់គ្រងរបស់អតិថិជនត្រូវបានពង្រឹង និងបានពង្រីកឱ្យកាន់តែមានភាពប្រសើរឡើងជាលំដាប់ធ្វើឱ្យការងារអាជីវកម្មអាចរកចំណូលបានច្រើន និងធានាបាននូវចំណាយសម្រាប់ដំណើរការផលិតនិងការផ្គត់ផ្គង់ទឹកដោយពុំចាំបាច់មានជំនួយពីខាងក្រៅ។

ដោយឆ្លងកាត់នៃការវិវត្តឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយទើបក្នុងឆ្នាំ១៩៩៦ អង្គភាពនេះ ត្រូវបានប្រកាសតែងតាំងនិងបានធ្វើការប្រសិទ្ធនាមជាថ្មីម្តងទៀតថា( រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ )គឺជាគ្រឹះស្ថានសាធារណៈ ដែលល្អប្រសើរមួយប្រកបដោយលក្ខណៈ គ្រឹះស្ថានឧស្សាហកម្មតាមអនុក្រឹតលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ *រ.ទ.ស.ភ* សហគ្រាសនីតិបុគ្គលមួយប្រកបដោយ**
អង្គភាពនេះមានភារកិច្ចសំខាន់ដូចខាងក្រោម៖

១/ ផលិត និងផ្គត់ផ្គង់ ទឹកស្អាតសម្រាប់បម្រើរាល់តម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញទាំងមូល។

២/ ការធានាលើតុល្យភាពចំណូលរួមទាំងចំណាយទាំងអស់ចំពោះដំណើរការនៃការផលិតរួមទាំង និងការវិនិយោគ នៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួនដោយមានប្រកាន់ខ្ជាប់ឱ្យបាននូវគោលការណ៍និងរបៀបប្រកបកិច្ចការដូចគ្នាទៅនិងពាណិជ្ជកម្មទូទៅ។

ក្នុងន័យនេះ រ.ទ.ស.ភ ក៏ត្រូវទទួលស្វ័យភាពយ៉ាងទូលំទូលាយដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលបំណងបំពេញបេសកម្មឱ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណារក្សាទ្រព្យសម្បត្តិឱ្យបានគង់វង្សនិងលើកកម្ពស់បញ្ហាអនាម័យសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងមានសោភណភាពនៃរាជធានីភ្នំពេញក៏ដូចជារក្សាឱ្យមានការអភិវឌ្ឍ និងមានការរីកចម្រើនឈានទ្បើង។

**១. ដំណាក់កាលពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩**

- **ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥**

បន្ទាប់ពីសម័យសង្គមរាស្ត្រនិយមបានដួលរលំនៅចុងឆ្នាំ១៩៦៩ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែររបស់លោក **លន់ នល់** ស្ថានភាពទូទៅនៅក្នុងស្រុក ព្រមទាំងសង្គមកិច្ច និងសេដ្ឋកិច្ចបានធ្លាក់ចុះអន់ថយធើបលែងរួចហើយក្រសួង និងស្ថាប័ននានាពោរពេញដោយភាពចម្រូងចម្រាស់ជាពិសេសសង្គ្រាមបានបន្ទុចបង្អាក់គ្រប់វិស័យនានា ស្ទើរតែទាំងស្រុងប្រកបដោយអស្ថេរភាពគោលនយោបាយអសន្តិសុខមន្ត្រីរាជការ-កម្មករ បានបោះបង់ការងាររបស់ខ្លួន ឬការធ្វើដោយភាពខ្ជីខ្ជារ។ ដំណើរការផលិតកម្ម និងអាជីវកម្មរបស់រដ្ឋាករទឹកក្រុងភ្នំពេញក៏បានថយចុះដោយពុំអាចបន្តសម្រេចនូវ ផែនការនិងកម្មវិធីនានាដែលបានគ្រោងទុក។

ម្យ៉ាងវិញទៀត ក្នុងគម្រោងដែលមានការរៀបចំបានប្រែក្លាយរដ្ឋាករទឹកភ្នំពេញឱ្យទៅជាសហគ្រាសជាតិមានស្វ័យភាពពេញលេញក៏ត្រូវផ្អាកផងដែរ។ការអាក់ខានទាំងអស់នេះហើយ គឺបណ្តាមកពីឥទ្ធិពលដ៏អាក្រក់នៃការកើតឡើងនៅសង្គ្រាមស៊ីវិលដណ្តើមអំណាចគ្នា ដែលធ្វើឱ្យប្រទេសជាតិទាំងមូលត្រូវបានធ្លាក់ចុះទៅក្នុងវិបត្តិផ្សេងៗយ៉ាងធ្ងន់ធ្ងរពិបាកនិងធ្វើការស្រោចស្រង់វិញបាន។

- **ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩**

ដោយសោកនាដកម្មឥតឈប់ឈរនៅមុនពេល និងក្រោយពីការរំលំរបបលោក លន់ នល់ រួចមកសភាពការនៅក្នុងប្រទេសកម្ពុជាក៏រឹតតែបន្ថែមទម្ងន់យ៉ាងខ្លាំងក្លាឡើងថែមទៀត ជាពិសេសក្នុងការបោសសម្អាតទីក្រុងភ្នំពេញដោយពួកខ្មែរកុម្មុយនិស្ត ។ ពួកខ្មែរក្រហមក៏បានកាន់កាប់ទាំងស្រុងទៅលើទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយមានការកាប់សម្លាប់យ៉ាងរង្គាលមិនថា ចាស់ ក្មេង ព្រះសង្ឃព្រមទាំងមន្ត្រីរាជការនិស្សិតបញ្ញវន្តរួមទាំងប្រជាពលរដ្ឋទាំងស្លូតត្រង់ក្នុងរាជដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មិនតែប៉ុណ្ណោះពួកគេបានបង្ខំជន្លៀសប្រជាជនទាំងអស់ឱ្យចាក់ចេញពីទីក្រុងភ្នំពេញដោយគ្មានគោលដៅ។



ហេតុផលទាំងនេះហើយទើបធ្វើឱ្យទីក្រុងទាំងមូលត្រូវបានប្រែក្លាយទៅជាការគ្របដណ្តប់ដោយមានសភាពស្ងាត់ជ្រងំ និងសោកនាដកម្មគ្មានទីបញ្ចប់។ អ្វីៗគ្រប់យ៉ាងក៏ត្រូវបានបិទទ្វារចោលមិនថាតែក្រសួង ឬស្ថាប័ននានា សាលារៀន មន្ទីរពេទ្យ វត្តអារាម ជាពិសេសរដ្ឋាករទឹកក្រុងភ្នំពេញក៏ត្រូវរងការខូចខាតដោយការបាញ់ និងការដុតបំផ្លាញយ៉ាងដំណំពីសំណាក់ពួកខ្មែរក្រហម។

នៅក្នុងការអនុវត្តការងារចែកចាយទឹកស្អាតនៅតែបន្តិចបន្តួចប៉ុណ្ណោះ គឺត្រូវបានបង្រួបបង្រួមមកត្រឹមតែសម្រាប់ការប្រើប្រាស់ទៅកងទាហាន និងពួកកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមានចំនួនតិចតួចក្នុងទីក្រុងខ្មោចនេះ។ សកម្មភាពអាជីវកម្មត្រូវបានប្រានចោលទាំងស្រុងហើយប្រការ ដែលគួរឱ្យចាប់អារម្មណ៍គឺក្នុងចន្លោះជិត៤ឆ្នាំនៃរបបខ្មែរក្រហមនេះ រោងចក្រផលិតទឹកស្អាតទាំងបី ទាំងប្រព័ន្ធផលិតកម្ម និងប្រព័ន្ធចែកចាយ ការថែទាំ ត្រូវបានគេបំភ្លេចចោលទាំងស្រុង ហើយផលវិបាកបានធ្វើឱ្យមានភាពស្មុគស្មាញរហូតដល់ឆ្នាំ១៩៧៩។

- **ដំណាក់កាលពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៣**

ក្រោយពីពន្លឺសន្តិភាពបានកើតមានឡើងដោយសារកិច្ចចរចានៅទីក្រុងប៉ារីស ប្រទេសបារាំង ភាគីជម្លោះ ទាំងប្រទេសកុម្មុយនិស្ត មិនមែនកុម្មុយនិស្ត បានធ្វើការគាំទ្រដល់ផែនការស្វែងរកសន្តិភាពរបស់អង្គការសហប្រជាជាតិ។

ឧត្តមក្រុមប្រឹក្សាជាតិក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះនរោត្តមសីហនុ ដែលជាប្រធានបានរៀបចំឱ្យមានការបោះឆ្នោតជាសកលមួយនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ដែលឈានទៅរកការបញ្ចប់នូវសង្គ្រាមមួយដ៏រ៉ាំរៃដើម្បីឱ្យកម្ពុជាអាចស្តារ និងមានការអភិវឌ្ឍប្រទេសជាតិទៅតាមមាគ៌ាលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងទទួលបានការគាំទ្រពីអន្តរជាតិ។ ដូច្នេះហើយគ្រប់រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានធ្វើការកែទម្រង់ពេលនោះដែរ។ នៅក្នុងពេលនោះដែរ រដ្ឋាករទឹកភ្នំពេញក៏ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាផ្តោតទៅលើការយកចិត្តទុកដាក់ជាចម្បងដោយមានការគិតគូរ ឱ្យចូលរួមទាំងវិស័យបច្ចេកទេស និងមូលធន ពីរាជរដ្ឋាភិបាលនិងទទួលបានជំនួយពីបណ្តាប្រទេសជាមិត្តជាច្រើនដូចជា ព្រះរាជាណាចក្រជប៉ុន ប្រទេសបារាំង សហភាពសូវៀត។ឥណទានពីធនជានពិភពលោក និង

ធនធានអភិវឌ្ឍន៍អាស៊ីដើម្បីបុព្វហេតុក្នុងការជួយទ្រទ្រង់ក្នុងវិស័យសុខាភិបាល អនាម័យ ក៏ដូចជាវិស័យទឹកស្អាតនៅកម្ពុជាផងដែរ។

ទោះបីជាក្នុងរយៈពេលនោះទ្រព្យសម្ភារៈ និងឯកសារបច្ចេកទេសទាំងអស់ត្រូវបានខូចខាត និងកម្ទេចបំផ្លាញក៏ដោយក៏រដ្ឋាករទឹកក្រុងភ្នំពេញបានរៀបចំឱ្យមានដំណើរការឡើងវិញនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៩ ក្នុងស្ថានភាពដ៏លំបាកក្រៃលែង ពីព្រោះថាមន្ត្រីរាជការ អ្នកបច្ចេកទេស មួយចំនួនធំបានបាត់បង់ជីវិតក្នុងរបបប៉ុលពត ហើយដែលនៅមាននិយោជិតមួយចំនួនតូចតែប៉ុណ្ណោះ ដែលក្នុងនោះភាគច្រើនគ្រាន់តែជាអ្នកដែលធ្លាប់ធ្វើការតែមិនមែនជាអ្នកមានជំនាញការផងនោះត្រូវបានប្រមូលកៀងគរឱ្យបានបម្រើកិច្ចការឡើងវិញ។

### ៣.១.២ អង្គភាពសំខាន់ៗរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

#### ក. ក្រុមប្រឹក្សាភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ក្រុមប្រឹក្សាភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅក្នុងអាណត្តិនីមួយៗតែងតែត្រូវបានតែងតាំងដោយអនុក្រឹត្យ។ នៅក្នុងអនុក្រឹត្យតែងតាំងដំបូង ឯកឧត្តម ស៊ឹម ស៊ីថា ដែលត្រូវជាអតីតនាយកដ្ឋាននៃ រ.ទ.ស.ភ ត្រូវបានតែងតាំងជាសមាជិក តែត្រូវប្តូរមកជាឯកឧត្តម ឡុង ណារ៉ូ ដែលជាអគ្គនាយកដ្ឋានថ្មីរបស់ រ.ទ.ស.ភ វិញ យោងតាមអនុក្រឹត្យលេខ ៣៧៨ អនក្រ.តត ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២១ ស្តីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងសមាជិកក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាភិបាលអណត្តិទី៧របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានសមាសភាពដូចតទៅ៖

១. **ឯកឧត្តម ស៊ឹម ស៊ីថា** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាប្រធានក្រុមប្រឹក្សាភិបាល

២. **ឯកឧត្តម ឡុង ណារ៉ូ** អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាសមាជិកក្រុមប្រឹក្សាភិបាល

៣. **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកក្រុមប្រឹក្សាភិបាល

៤. **ឯកឧត្តម នួន ផារ័ត្ន** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាល

៥. **លោក ម៉ា ណូរ៉ាវីន** តំណាងនិយោជិតនៃ រ.ទ.ស.ភ ជាសមាជិកក្រុមប្រឹក្សាភិបាល

៦. **លោក ណាំ ចន្ទ្រី** អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនឯកជន ជាសមាជិកក្រុមប្រឹក្សាភិបាល

៧. **លោក ស្រេង សំឱក** អភិបាលឯករាជ ជាសមាជិកក្រុមប្រឹក្សាភិបាល។

#### ខ.អង្គភាពចំណុះ

អង្គភាពចំណុះរបស់ រ.ទ.ស.ភ មានចំនួន ៦ ដែលមានដូចជា៖

(១) អង្គភាពលេខាធិការសហគ្រាស

(២) លេខាធិការដ្ឋានដែលមានតួនាទីជាសេនាធិការរបស់អគ្គនាយកដ្ឋានលើរាល់ព័ត៌មានលិខិតស្នាម និងការងារក្រុមប្រឹក្សាភិបាល

(៣) សវនកកម្មផ្ទៃក្នុង

(៤) នីតិកម្ម និងអធិការកិច្ច

(៥) មណ្ឌលព័ត៌មានវិទ្យា

(៦) អង្គភាពលទ្ធកម្ម។

### គ.នាយកដ្ឋានរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

នាយកដ្ឋាននីមួយៗរបស់(រ.ទ.ស.ភ)ត្រូវបានដឹកនាំដោយអគ្គនាយករងមួយរូបដែលមានបន្ទុកទទួល ខុសត្រូវទៅលើនាយកដ្ឋាននោះ។

- **នាយកដ្ឋានផែនការ និងគម្រោង** មានការិយាល័យចំណុះ៤ ដែលមានដូចជា ការិយាល័យ ផែនការ ការិយាល័យសិក្សាគម្រោងការិយាល័យគ្រប់គ្រងគម្រោងនិងការិយាល័យប្លង់ប្រព័ន្ធចែកចាយទឹក។
- **នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម** មានការិយាល័យចំណុះ ៣ ដែលមានដូចជា ការិយាល័យ ផលិតកម្ម(រោងចក្រភូមិព្រែក រោងចក្រជ្រោយចង្វារ រោងចក្រចំការមន រោងចក្រនិរោធ រោងចក្រ ត្បូងឃ្មុំ និងរោងចក្រម្ដេច) ការិយាល័យយន្តសាស្ត្រ និងអគ្គិសនី និងមន្ទីរពិសោធន៍ទឹក។
- **នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក** មានការិយាល័យចំណុះ ៣ ដែលមានដូចជាការិយាល័យ ស្រាវជ្រាវទឹកបាត់បង់ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក និងការិយាល័យថែទាំប្រព័ន្ធមេនាំទឹក។
- **នាយកដ្ឋានអាជីវកម្ម** មានការិយាល័យចំណុះ ១៣ ដែលមានដូចជា ការិយាល័យបណ្តាញចូល ផ្ទះ ការិយាល័យទំនាក់ទំនងអតិថិជន ការិយាល័យចំណូលដូនពេញ ការិយាល័យចំណូល៧មករា ការិយាល័យចំណូលចំការមន ការិយាល័យចំណូលទួលគោក ការិយាល័យចំណូលឫស្សីកែវ ការិយាល័យចំណូលសែនសុខ ការិយាល័យចំណូលមានជ័យ ការិយាល័យចំណូលដង្កោ ការិយាល័យចំណូលពោធិ៍សែនជ័យ ការិយាល័យចំណូលតាខ្មៅ និងការិយាល័យចំណូលច្បារអំពៅ។
- **នាយកដ្ឋានគណនេយ្យ** និងហិរញ្ញវត្ថុ មានការិយាល័យចំណុះ ៣ ដែលមានដូចជា ការិយាល័យ ទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ការិយាល័យគណនេយ្យ និងការិយាល័យហិរញ្ញវត្ថុ។
- **នាយកដ្ឋានរដ្ឋបាល** និងធនធានមនុស្ស មានការិយាល័យចំណុះ ២ ដែលមានដូចជា ការិយាល័យ ២ធនធានមនុស្ស។
- **សាខាសេវាកម្មទឹកស្អាត** និងអនាម័យ មានការិយាល័យចំណុះ ៥ ដែលមានដូចជា ការិយាល័យ ប្រឹក្សាបច្ចេកទេស និងគ្រប់គ្រង ការិយាល័យអនុវត្តសំណង់ទូទៅ ការិយាល័យបណ្តាញមេនាំទឹក ការិយាល័យបណ្តាញចែកចាយទឹក និងការិយាល័យទីផ្សារ និងសេវាកម្ម។

## ៣.១.៣ គោលនយោបាយរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ក. គោលនយោបាយ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ) ត្រូវបានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសវនកម្មរបស់ខ្លួនរៀងរាល់ប្រចាំឆ្នាំសេវាសវនកម្ម ដើម្បីឆ្លើយតបតម្រូវការជាច្រើនរបស់អតិថិជន និងដើម្បីធានានូវភាពរឹងមាំផ្នែកហិរញ្ញវត្ថុ។ សេវាកម្មនេះគឺជានាគុណភាពខ្ពស់របស់ CPA ដែលសវនកម្មត្រូវបានអនុវត្ត ស្របតាមស្តង់ដាសវនកម្មដែលគេទទួលយក។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ) ក៏បានផ្តល់ជូនសេចក្តីថ្លែងការណ៍ដែល បានត្រួតពិនិត្យមើលថាការពិនិត្យមើលឡើងវិញ ត្រូវបានអនុវត្តស្របតាមបទដ្ឋានវិជ្ជាជីវៈ សម្រាប់ការខ្ចីលុយពីធនាគារការវិនិយោគខាងក្រៅ និងម្ចាស់បំណុលពាណិជ្ជកម្មណាដែលមិនត្រូវការរបាយការណ៍ហិរញ្ញវត្ថុ។ការស៊ើបអង្កេតភាគច្រើនត្រូវបានធ្វើឡើងពីការចងក្រងខាងលើ។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាមួយ នឹងការប្រើប្រាស់បុគ្គលិក និងអ្នកគ្រប់គ្រងទៅតាមតួនាទីរៀងៗខ្លួនហើយប្រព័ន្ធគណនេយ្យរួមបញ្ចូលគ្នាតាមកុំព្យូទ័រ។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានដំណើរការបញ្ជីប្រាក់បៀវត្ស ការគណនាពន្ធកាត់ទុករបស់បុគ្គលិក និងកំណត់ត្រាពន្ធ។ជាពិសេសអាចកំណត់ត្រាចំនួនសារពើពន្ធទាំងអស់ ដើម្បីរៀបចំការតភ្ជាប់គណនីផ្សេងៗឱ្យដូចទៅ នឹងប្រព័ន្ធនៃការតភ្ជាប់របស់ធនាគារ និងសេវាកម្មគណនេយ្យផ្សេងទៀតដែលចាត់ទុកជាការចាំបាច់សម្រាប់អតិថិជន។

**ខ. ទស្សនវិស័យ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ) បានប្តេជ្ញាចិត្តនឹងបន្តធ្វើការឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្ររបស់ខ្លួនឱ្យកាន់តែមានការរីកចម្រើនប្រកបដោយស្ថេរភាពព្រមទាំងផ្តល់អត្ថប្រយោជន៍ឱ្យទៅដល់អ្នកវិនិយោគ ពិសេសផ្តល់ចំណូលដល់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា និងផ្តល់ការងារផ្សេងៗទៀតជាច្រើនដល់ប្រជាពលរដ្ឋថែមទៀតផង។

**គ. បេសកកម្ម**

សម្រាប់បេសកកម្មនៅក្នុងវិស័យជួញដូរមូលបត្រវិញ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក៏បានយល់ដឹងពីអត្ថប្រយោជន៍ដែលត្រូវផ្តល់ជូនទៅកាន់អ្នកវិនិយោគ និងចំណូលដែលត្រូវផ្តល់ជូនរដ្ឋផងដែរ។ក្រុមហ៊ុនបានពង្រឹងការផ្សព្វផ្សាយ និងការជួញដូរឱ្យកាន់តែមានភាពរីកចម្រើន និងដំណើរការទៅមុខជានិច្ច ដើម្បីកំណត់គោលដៅបោះផ្សាយមូលបត្រជារៀងរាល់ឆ្នាំ។

**ឃ. ចក្ខុវិស័យ**

រ.ទ.ស.ភ បានប្តេជ្ញាចិត្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាពព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សាជាអ្នសម្របសម្រួល ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្តក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

## ពានរង្វាន់







ផែនការមេ




ហិរញ្ញវត្ថុ

ង.រចនាសម្ព័ន្ធ

# រចនាសម្ព័ន្ធអង្គភាព




## ៣.២ ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.២.១ ដំណើរការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ក. លក្ខខណ្ឌក្នុងការបោះផ្សាយមូលបត្រ

❖ ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោមមក ផ.ម.ក. ៖

**១- ព័ត៌មានទូទៅ**

- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង។
- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។
- កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។
- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

**២-ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ**

អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ

**៣-ព័ត៌មានអំពីភាគហ៊ុនិក**

អត្តសញ្ញាណភាគហ៊ុនិក។

**៤-ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន**

- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត។
- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។
- ការវាយតម្លៃទ្រព្យសកម្ម និង/ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ( ប្រសិនបើមាន )។
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**៥-ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន**

- ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច។
- ព័ត៌មានអំពីហានិភ័យ។

**៦-ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។**

**៧-ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។**

❖ ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក

- ដ្យាក្រាមនៃដំណើរកាលនៃការចុះបញ្ជី



**ខ. សង្ខេបអំពីមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់**

1) ឈ្មោះក្រុមហ៊ុនបោះផ្សាយ : រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

2) ឈ្មោះក្រុមហ៊ុនធានាទិញមូលបត្រ : ក្រុមហ៊ុនគុងយ៉ាង ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី

3) ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ៦.៣០០ រៀល (តម្លៃចារឹក ១.០០០ រៀល)

4) ប្រភេទមូលបត្រកម្មសិទ្ធិ មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត (ភាគហ៊ុនធម្មតា)

5)ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបោះផ្សាយលក់ ១៣.០៤៥.៩៧៥ (អត្រាបោះផ្សាយ ១៥%)

6) ចំនួនមូលបត្រកម្មសិទ្ធិសរុបមុន អាយ ភី អូ ៧៣.៩២៧.១៨៧ ភាគហ៊ុនធម្មតា និង ៣៩១.១០០.៩៤២ ភាគហ៊ុនប្រភេទ "ក"

7) ចំនួនមូលបត្រកម្មសិទ្ធិសរុបក្រោយ អាយ ភី អូ ៨៦.៩៧៣.១៦២ ភាគហ៊ុនធម្មតា និង ៣៩១.១០០.៩៤២ ភាគហ៊ុនប្រភេទ "ក"

8) ចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយ : ៨២.១៨៩.៦៤២.៥០០ រៀល

**គ. លក្ខខណ្ឌសម្រាប់ទីផ្សារគោល** (Main Board)

- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ ( សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក. ។
- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំ សារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់ លាន) រៀល សម្រាប់រយៈពេល ២(ពីរ) ឆ្នាំចុងក្រោយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់ កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេង ពីនេះដោយអគ្គនាយកនៃ គ. ម. ក. តាមការស្នើសុំរបស់ ផ. ម. ក. ។
- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមាន សិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ. ម. ក. តាមការស្នើសុំរបស់ផ.ម.ក. ។

**ឃ. ឯកសារដែលត្រូវផ្តល់ជូន គ.ម.ក**

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ គ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវផ្តល់ជូន គ.ម.ក. នូវឯកសារ ដូចខាងក្រោម៖

- ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក. ។
- ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។
- ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។
- ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

- របាយការណ៍បែងចែកមូលបត្រ។
- លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិករក្សាទុកមូលបត្រ។

**ខ.យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងអនុលោមតាមព្រះរាជក្រម**

លេខ នស/រកម/១០០៧/ ០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសដោយ ឲ្យប្រើច្បាស់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹតលេខ ៥៤ អនក្រ. បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះ ផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១០ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃ ទៀត និងដើម្បីសម្រួលដល់ការយល់ដឹងជានាឲ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងដំណើការនៃការ បោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) បានធ្វើ ការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងដែលរួមមានដូចខាង ក្រោម៖

**១-ការដាក់លិខិតសម្តែងឆន្ទះបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈអាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈជូនមក គ.ម.ក ដែលលិខិតមានខ្លឹមសារ ០៣ចំណុចដូចខាងក្រោម៖

១-គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈដំបូង(Purpose of IPO)។

២-គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសធារណៈលើកដំបូង (Expected Timetable)។

៣-ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងដែលរំពឹងទុករួមមានក្រុមហ៊ុនធានាទិញមូលបត្រក្រុមហ៊ុនគណនេយ្យជំនាញមេធាវីឬក្រុមមេធាវីនិងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

**២-ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ**

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណើរការដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រត្រូវផ្តល់សេវាកម្មដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ ជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក។

**៣-ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង (IPO Team)**

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀតដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវីនិងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ដើម្បីចូលរួមការងារបោះផ្សាយលក់កម្មសិទ្ធជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង។

**៤-ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់( (Due Diligence)**

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ជាដំណាក់ការដ៏សំខាន់និងចាំបាច់បំផុត។ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយ លក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញមេធាវីឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

**៥-ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនិងការទទួលបានបញ្ជាក់ពីលទ្ធភាពអាច ចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**៦-ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលការអនុញ្ញាតជាគោល ការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក**

ក្រោយពីទទួលបានការបញ្ជាក់ ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះ ផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក។ គ.ម.ក ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់ មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មានមុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើ សំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

**៧-ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រ ជាសាធារណៈពីគ.ម.កក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំធ្វើការកំណត់ ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុ ពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**8-ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើរលក់ (Term of Offer) និងការទទួលបានការអនុញ្ញាតនិង ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីគ.ម.ក**

ក្រោយពីបានការបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់ជាមួយលិខិតបញ្ជាក់ការវាយតំលៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជារួចដាក់ជូន គ.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**9-ការធ្វើបរិវិសកម្មមូលបត្រ(Subscription)**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្ម មូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌដូចមានចែង ក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាស ស្តីពីការបោះ ផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈ។

**១០-ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន គ.ម.ក។

**៣.២.២ ដំណើរការជួញដូរមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ក.ដំណាក់កាលនៃការជួញដូរ**

❖ការត្រៀមខ្លួនមុនពេលជួញដូរ

✦ ការកំណត់អំពីគោលបំណង

វិនិយោគិនអាចប្រឹក្សាជាមួយនឹងក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលមានបទពិសោធន៍ និងគុណវុឌ្ឍដើម្បីជួយបង្កើតនូវគោលបំណងវិនិយោគឬធ្វើការសាកល្បងលើយោបល់របស់ក្រុមហ៊ុនទាំងនោះ។ ការប្រឹក្សានេះអាចជួយឲ្យវិនិយោគិនវាយតម្លៃលើគោលបំណងដែលអាចទុកចិត្តបាន និងកម្រិតហានិភ័យដែល នឹងអាចកើតមានលើការវិនិយោគនេះ។

វិនិយោគិនគួរពិចារណាលើពាក្យស្លោកដែលបានលើកឡើង៖

-ការវិនិយោគដែលមានហានិភ័យខ្ពស់នោះប្រាក់ចំណេញអាចទទួលបានក៏ខ្ពស់ដែរ( High risk, high return )

-គួរកុំប្រថុយវិនិយោគលើគម្រោងវិនិយោគតែមួយ ( Don't put all your eggs in one basket )

-សាច់ប្រាក់អាចបង្កើតសាច់ប្រាក់បាន ( Money makes Money )។

✦ **ការស្នើសុំអត្តសញ្ញាណវិនិយោគិន**

✓ វិនិយោគិនអាចស្នើសុំលេខអត្តសញ្ញាណវិនិយោគិនដោយផ្ទាល់នៅ គ.ម.កឬតាមរយៈក្រុមហ៊ុនមូលបត្រ។
✓ លេខអត្តសញ្ញាណវិនិយោគិនមានសុពលភាពរយៈពេល១០ឆ្នាំ។
✓ កម្រៃនៃការដាក់ស្នើសុំលេខអត្តសញ្ញាណវិនិយោគិនរូបវន្តបុគ្គល ២០.០០០រៀល។
✓ វិនិយោគិនអាចស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាព ៣ ខែ។ វិនិយោគិនម្នាក់អាចមានអត្តសញ្ញាណវិនិយោគិនតែមួយគត់។

✦ **ការបើកគណនីជួញដូរមូលបត្រ**

✓ ក្រោយពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន វិនិយោគិនអាចបើកគណនីជួញដូរមូលបត្រនៅក្រុម ហ៊ុនមូលបត្រ។

- ✓ កិច្ចព្រមព្រៀងរវាងវិនិយោគិន និងក្រុមហ៊ុនមូលបត្រត្រូវធ្វើឡើង ដោយវិនិយោគិនត្រូវផ្តល់ព័ត៌មានស្រប តាម KYC rule (Know Your Client)។ ជាមួយគ្នានេះ អតិថិជនត្រូវដាក់តម្កល់សាច់ប្រាក់មូលបត្រ ដើម្បីធ្វើការជួញដូរមូលបត្រ។
- ✓ ក្រុមហ៊ុនមូលបត្រត្រូវយកសាច់ប្រាក់ដែលអតិថិជនដាក់តម្កល់នោះដាក់ក្នុងគណនីសាច់ប្រាក់អតិថិជន (Client Money Account) នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដាក់ដោយឡែកពី គណនីសាច់ប្រាក់ផ្ទាល់ខ្លួនរបស់ ក្រុមហ៊ុនមូលបត្រ។ ចំពោះមូលបត្រត្រូវដាក់តម្កល់ក្នុង ប្រតិបត្តិការ រក្សា ទុកមូលបត្រ។

**✦ ការជ្រើសរើសក្រុមហ៊ុនមូលបត្រ**

វិនិយោគិនអាចជ្រើសរើសក្រុមហ៊ុនមូលបត្រដែលខ្លួនពេញចិត្ត ដោយគួរតែពិចារណាលើកត្តាដូចខាងក្រោម៖

- ➢ សេវាកម្ម(Services)
- ➢ កម្រៃជើងសារ (Commission)
- ➢ សិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជនក្នុងកិច្ចព្រមព្រៀងរវាងវិនិយោគិន និងក្រុមហ៊ុនមូលបត្រ។

**❖ ការវិនិយោគនៃកាជួញដូរ**

តើអ្នកទិញ-លក់មូលបត្រដូចម្តេច?

វិនិយោគិនអាចទិញមូលបត្រនៅក្នុងទីផ្សារដំបូង(Primary Market)

ក្រោយពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន និងលេខគណនីជួញដូរហើយអតិថិជនអាចធ្វើការជួញដូរមូលបត្របាន។

**❖ ការធ្វើឲ្យកាន់តែប្រសើរលើការវិនិយោគ**

ក្រោយពីបានវិនិយោគក្នុងទីផ្សារមូលបត្រ ទាក់ទងនឹងការជួញដូរមូលបត្រ វិនិយោគិនទទួលបានបទពិសោធន៍និងចំណេះដឹង ដូចនេះវិនិយោគិនគួរមានសកម្មភាពដូចខាងក្រោមបន្ថែមទៀត៖

- ✓ ពិនិត្យឡើងវិញលើគោលបំណងដែលអ្នកបានកំណត់មុនពេលជួញដូរ និងរៀបចំគោលបំណង និងយុទ្ធសាស្ត្រ ក្នុងការវិនិយោគរបស់អ្នកដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង។
- ✓ បន្តសិក្សា និងស្វែងយល់ពីទីផ្សារមូលបត្រ ការវិនិយោគលើទីផ្សារមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត តាមរយៈការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងស្វ័យសិក្សាជាដើម។
- ✓ គប្បីតាមដានព័ត៌មានទាក់ទងនឹងវិស័យមូលបត្រជាពិសេស ទាក់ទងនឹងក្រុមហ៊ុនបោះផ្សាយលក់ មូលបត្រ ដែលអ្នកបានកាន់កាប់មូលបត្រ។ (ឯកសារផ្តល់ព័ត៌មាន និងឯកសារផ្តល់ព័ត៌មានជាប្រចាំ)។
- ✓ ការតាមដានព័ត៌មានសេដ្ឋកិច្ច រួមមានកំណើនសេដ្ឋកិច្ច អត្រាការប្រាក់ គោលនយោបាយសេដ្ឋ កិច្ចរបស់ រដ្ឋាភិបាល...។
- ✓ ធ្វើជាភាគហ៊ុននិកដែលមានការទទួលខុសត្រូវ។

✓ ត្រៀមធ្វើការជួញដូរ និងជួញដូរលើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ឬបង្កើតជាផលបត្រ (Portfolio)។

✓ ចៀសវាងក្លាយខ្លួនជាជនរងគ្រោះពីការឆបោក(Don't be a fraud victim)។

**ខ. ដំណើរការជួញដូរមូលបត្រ**

❖ **ថ្ងៃជួញដូរ**

- ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ)។

❖ **ម៉ោងជួញដូរ**

- ការជួញដូរចាប់ផ្តើមពីម៉ោង ០៨:០០ ព្រឹក រហូតដល់ម៉ោង ១១:៣០ ព្រឹក។ ការអនុវត្តការជួញដូរមានពីរដងក្នុងមួយថ្ងៃគឺនៅម៉ោង០៩:០០ព្រឹក និងម៉ោង១១:៣០ព្រឹក។
- ម៉ោងជួញដូរ ចាប់ផ្តើមពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល ដែលមានលម្អិតដូច ខាងក្រោមៈ
  - ម៉ោងជួញដូរពីម៉ោង ៨:០០-៩:០០ ព្រឹក ប្រើប្រាស់វិធីសាស្រ្តដេញថ្លៃដោយយកថ្លៃ តែមួយ ដែលការផ្គូផ្គងនឹងប្រព្រឹត្តទៅនៅម៉ោង ៩:០០ ព្រឹក
  - ម៉ោងជួញដូរពីម៉ោង ៩:០០ ព្រឹក-២:៥០ រសៀល ប្រើប្រាស់វិធីសាស្រ្តដេញថ្លៃ ដោយយកថ្លៃច្រើន ដែលការផ្គូផ្គងត្រូវធ្វើឡើងភ្លាមៗនៅពេលបញ្ជាជួញដូរត្រូវគ្នា (វគ្គជួញដូរនិរន្តរ៍)
  - ម៉ោងជួញដូរពីម៉ោង ២:៥០-៣:០០ រសៀល ប្រើប្រាស់វិធីសាស្រ្តដេញថ្លៃដោយយកថ្លៃតែមួយ ដែលការផ្គូផ្គងនឹងប្រព្រឹត្តទៅនៅម៉ោង ៣:០០ រសៀល
  - រូបិយប័ណ្ណរៀល។




❖ **ថ្លៃមូលដ្ឋាន**

ជាទូទៅថ្លៃមូលដ្ឋាន គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។ ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្ម សិទ្ធិចុះបញ្ជីលក់ដំបូងត្រូវស្ថិតនៅចន្លោះ៩០%និង១៥០% នៃថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាលើកដំបូង (ថ្លៃIPOដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅគ.ម.ក.)។ ក្នុងករណីដែល មានសិទ្ធិកម្មសិទ្ធិករមូលបត្រដូចជាការបង្កើន ឬបន្ថយមូលធនការបែងចែក ភាគលោកជាភាគហ៊ុនការបំបែក ភាគហ៊ុន។ល។ នោះថ្លៃមូលដ្ឋាននឹងត្រូវបានគណនា ដោយស្វ័យប្រវត្តិដោយប្រព័ន្ធរបស់

ផ.ម.ក.តាមរយៈការប្រើប្រាស់នូវរូបមន្តមួយជាក់លាក់។ ក្នុងករណីថ្លៃមូលបត្រ ដែលបានគណនាទាបជាង ឯកតាគម្លាតថ្លៃនោះ ថ្លៃមូលដ្ឋានត្រូវបង្កត់ឡើងអោយស្មើនឹងឯកតាគម្លាតថ្លៃ។

❖ **ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ**

ឯកតានៃរាល់ការដាក់បញ្ជាទិញ/លក់ មូលបត្រកម្មសិទ្ធិ គឺ ០១ (មួយ) ភាគហ៊ុន។

ឯកតា នៃការជួញដូរ មូលបត្រកម្មសិទ្ធិអប្បបរមា ចាប់ពី ០១ (មួយ) ភាគហ៊ុន។

ចលនានៃថ្លៃ ត្រូវបានផ្អែកលើ ថ្លៃឯកតា (គម្លាតថ្លៃ) នៃតារាងតម្លៃ ដូចខាងក្រោម: (ទឹក ប្រាក់ទាំងអស់គឺជាប្រាក់រៀល)។

❖ **កម្រិតនៃបម្រែបម្រួលថ្លៃ**

- ថ្លៃជួញដូរដំបូងបន្ទាប់ពីថ្លៃ IPO ត្រូវស្ថិតនៅក្នុងចន្លោះពី ៩០% ទៅ ១៥០% (ត្រូវបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅគណៈកម្មការមូលបត្រកម្ពុជា)។
- បម្រែបម្រួលថ្លៃស្ថិតនៅចន្លោះ១០% នៃថ្លៃមូលដ្ឋាន។ ក្នុងករណីថ្លៃទាបជាង ២០០រៀល បម្រែបម្រួលថ្លៃប្រចាំថ្ងៃគឺ១០រៀល។
- ថ្លៃមូលដ្ឋានត្រូវកំណត់ពីថ្លៃបិទផ្សារកាលថ្ងៃម្សិលមិញ (ឬថ្ងៃជួញដូរចុងក្រោយកន្លងមក)។
- ក្នុងករណីមានសកម្មភាពអាជីវកម្ម ដូចជា ការបង្កើនឬបន្ថយដើមទុន ការបែងចែកភាគលាភ ការបែងចែកសិទ្ធិ, split off ។ល។ ថ្លៃមូលដ្ឋានត្រូវគណនាជាស្វ័យប្រវត្តិ ដោយ ប្រព័ន្ធរបស់ផ្សារមូលបត្រកម្ពុជាតាមរូបមន្តជាក់លាក់។
- នៅពេលថ្លៃដែលបានគណនាហើយទាបជាងថ្លៃឯកតា (គម្លាតថ្លៃ) ត្រូវបានបង្កើនបង្គប់ទៅតាមថ្លៃឯកតា។

❖ **ការផ្គូផ្គងដោយយកថ្លៃតែមួយ**

- អាទិភាពនៃសំណើទិញ/លក់

1. **ថ្លៃ**
   - សំណើលក់ដែលមានថ្លៃទាបមានអាទិភាពជាងសំណើលក់ដែលមានថ្លៃខ្ពស់
   - សំណើទិញដែលមានថ្លៃខ្ពស់មានអាទិភាពជាងសំណើទិញដែលមានថ្លៃទាប។
2. **ពេលវេលា**
   - ករណីសំណើដែលមានថ្លៃដូចគ្នា សំណើដែលទទួលបានមុន មានអាទិភាពជាងសំណើដែលទទួល បានក្រោយ។
3. **ទំហំជួញដូរ**
   - សំណើដែលមានទំហំជួញដូរធំ មានអាទិភាពជាង នៅពេលដែលសំណើបានដាក់នៅម៉ោង និងថ្លៃ ដូចគ្នា។
4. **សំណើក្នុងពេលដំណាលគ្នា**
   - សំណើពីគណនី អតិថិជនមានអាទិភាពជាងសំណើពីគណនីផ្ទាល់ខ្លួនរបស់ក្រុមហ៊ុនមូលបត្រ។

- សំណើមួយមានប្រសិទ្ធភាពនៅពេលដែលវាត្រូវបានបញ្ចូលក្នុងប្រព័ន្ធនៃការជួញដូររបស់ផ្សារមូល។

❖ **យន្តការការជួញដូរ**

1) វិនិយោគិនបើកគណនីជួញដូរ (គណនីសាច់ប្រាក់និងគណនីមូលបត្រ) នៅក្រុមហ៊ុនមូលបត្រមួយ នៅមួយថ្ងៃមុនថ្ងៃជួញដូរ។
2) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជា (ទិញឬលក់) ទៅកាន់ក្រុមហ៊ុនមូលបត្រ ជាលាយលក្ខណ៍អក្សរពាក្យសំដី (ថតទុក) ឬមធ្យោបាយអេឡិចត្រូនិចនានា។
3) ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ ផ.ម.ក. ប៉ុន្តែមុននឹងដាក់បញ្ជាក្រុម ហ៊ុនមូលបត្របានបង្កកទុករួចហើយនូវសាច់ប្រាក់ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយនៃបញ្ជានីមួយៗ។
4) បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញ ថ្លៃដែលបានកំណត់ទុកជាមុន។
5) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។
6) ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួន (នៅ T+0)។
7) ក្នុងករណីមានកំហុសឆ្គងប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ផ.ម.ក.ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃT+1។បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយដំណើរការក្នុងចំនុចទី៥ និងទី៦នឹងត្រូវអនុវត្តម្តងទៀត។
8) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែង គឺក្រុមហ៊ុន មូលបត្រប្រើប្រាស់សាច់ប្រាក់ឬមូលបត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីទូទាត់ ដោយសុំឬមិនបាច់ សុំការអនុញ្ញាតពីអតិថិជនឡើយ។
9) ទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ ផ.ម.ក។

**គ. លទ្ធផលនៃការជួញដូររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

✦ **តម្លៃភាគហ៊ុន**

| កាលបរិច្ឆេទ | ថ្លៃបិទ | បម្រែបម្រួល | ទំហំជួញដូរ (ភាគហ៊ុន) | តម្លៃជួញដូរ (រៀល) | ថ្លៃបើក | ថ្លៃខ្ពស់ | ថ្លៃទាប | មូលធន.ទីផ្សារ(លានរៀល) | មូលធន .ទីផ្សារពេញ (លានរៀល) |
|---|---|---|---|---|---|---|---|---|---|
| 31/12/2021 | 7,160 | ▼40 | 925 | 6,650,740 | 7,280 | 7,280 | 7,100 | 622,728 | 3,423,011 |
| 30/12/2021 | 7,200 | ▲140 | 43,125 | 306,228,580 | 7,060 | 7,260 | 7,060 | 626,207 | 3,442,134 |
| 29/12/2021 | 7,060 | ▲20 | 3,504 | 24,731,320 | 7,040 | 7,080 | 7,040 | 614,031 | 3,375,203 |

# ក្រាហ្វិកចុងឆ្នាំ ២០២១



## ៣.៣ ផលប្រយោជន៍នៃការបោះផ្សាយមូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.៣.១ ផលប្រយោជន៍ចំពោះក្រុមហ៊ុន




ការបោះផ្សាយមូលបត្រផ្តល់ប្រយោជន៍សំខាន់ដល់ក្រុមហ៊ុនដូចជា៖

- ពង្រីកប្រតិបត្តិការអាជីវកម្ម៖ ធ្វើឱ្យមានការកើនឡើងនូវការចូលរួមបោះផ្សាយពីសំណាក វិនិយោគិនមួយចំនួន
- ទទួលបានកេរ្តិ៍ឈ្មោះ៖ ធ្វើឱ្យក្រុមហ៊ុនមានភាពល្បីល្បាញ និងមានអ្នកស្គាល់ក្រុមហ៊ុន កាន់តែច្រើនឡើង
- ទាក់ទាញបុគ្គលិក៖ នៅពេលដែលក្រុមហ៊ុនមានសក្តានុភាពខ្លាំង តែងតែជាចំណាប់ អារម្មណ៍របស់បុគ្គលិកដែលមានសមត្ថភាព និងមានជំនាញច្បាស់លាស់ដើម្បីចូលបម្រើ ការងារប្រាកដណាស់
- យុទ្ធសាស្ត្រចាកចេញ៖ ការប្រើប្រាស់វិធានការដើម្បីទប់ស្កាត់ការចាកចេញរបស់វិនិយោគ មួយចំនួន និងប្រើប្រាស់វិធីសាស្ត្រស្រូបទាញឱ្យមានប្រសិទ្ធភាព
- ការលើកទឹកចិត្តផ្នែកពន្ធដារ។

### ៣.៣.២ ផលប្រយោជន៍ចំពោះអ្នកវិនិយោគ



ការបោះផ្សាយមូលបត្រផ្តល់ប្រយោជន៍សំខាន់ដល់អ្នកវិនិយោគដូចជា៖

- នៅពេលដែលវិនិយោគិនម្នាក់ទិញភាគហ៊ុនពីក្រុមហ៊ុនចុះបញ្ជីលក់ភាគហ៊ុនណាមួយ គាត់នឹងទទួលបានភាពជាម្ចាស់កម្មសិទ្ធិមួយផ្នែកនៅក្នុងក្រុមហ៊ុននោះ។ គាត់មានសិទ្ធិក្នុងការបោះឆ្នោតលើគោលនយោបាយនៃក្រុមហ៊ុននោះ ឬចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុន ព្រមទាំង ចូលរួម ទទួលនូវការចែករំលែកភាពជោគជ័យ ឬ បរាជ័យ នៃអាជីវកម្មរបស់ក្រុមហ៊ុនជាដើម។ ការវិនិយោគលើភាគហ៊ុនជារឿយៗផ្តល់ឱ្យវិនិយោគិននូវចំណូលខ្ពស់បើប្រៀបទៅនឹងការវិនិយោគលើវិស័យផ្សេងៗទៀត។
- ភាពងាយស្រួលជួញដូរ៖ រាល់ភាគហ៊ុននីមួយៗ ផ្តល់ឱ្យវិនិយោគិននូវប្រាក់ចំណូលជាទម្រង់ភាគលាភដែលត្រូវផ្តល់ដោយក្រុមហ៊ុនចុះបញ្ជីលក់ភាគហ៊ុនមួយ។ភាគហ៊ុនអាចត្រូវបានជួញដូរក្នុងបរិមាណតូចហើយដែលមានតម្លៃសមរម្យសម្រាប់វិនិយោគិនគ្រប់រូប។ វិនិយោគិនក៏អាចលក់ភាគហ៊ុនរបស់ពួកគេនៅក្នុងទីផ្សារមូលបត្រ ហើយទទួលបានប្រាក់វិញយ៉ាងឆាប់រហ័ស។
- ទទួលបាននូវប្រាក់ចំណេញ នៅពេលថ្លៃភាគហ៊ុនកើនឡើង។ទទួលបាននូវការវិនិយោគថ្មីមួយទៀត បន្ថែមពីវិនិយោគផ្សេងៗ និងអាចជ្រើសរើសភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងវិស័យខុសៗគ្នា ឬអាចនិយាយថាជាឱកាសវិនិយោគមួយបន្ថែមទៀតលើការបើកអាជីវកម្មរកស៊ីខ្លួនឯង ឬចូលហ៊ុនធ្វើអាជីវកម្មជាមួយបងប្អូនឬមិត្តភ័ក្តិ។អត្ថប្រយោជន៍មូលបត្រមានប្រភពចំណូលបន្ថែម បន្ទាប់ពីការងារប្រចាំថ្ងៃ ដោយវិនិយោគិននឹងអាចទទួលបានភាគលាភ ទៅតាមស្ថានភាពសារជីវកម្មរបស់ក្រុមហ៊ុន។
- បង្កើនចំណេះដឹងផ្នែកមូលបត្រ និងទទួលបានការលើកទឹកចិត្តពន្ធដារថែមទៀតផង។

**៣.៣.៣ ផលប្រយោជន៍ចំពោះសេដ្ឋកិច្ចជាតិ**




ការបោះផ្សាយមូលបត្រផ្តល់ប្រយោជន៍សំខាន់ដល់សេដ្ឋកិច្ចជាតិដូចជា៖

- កំណើនសេដ្ឋកិច្ចជាតិ៖ ក្រុមហ៊ុនបោះផ្សាយអាចជំរុញការវិនិយោគបន្ថែមរបស់ខ្លួនតាមរយៈការបង្កើនទុនពីទីផ្សារមូលបត្រសម្រាប់អនុវត្តគម្រោងវិនិយោគដែលមានផលិតកម្មខ្ពស់ដែលអាចឈានទៅដល់ការបង្កើនមូលធននិងនាំឱ្យមានកំណើនសេដ្ឋកិច្ច ។
- ការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល៖ តាមរយៈទីផ្សារមូលបត្ររាជរដ្ឋាភិបាលអាចដាក់ ចេញនូវគោលនយោបាយនានារបស់ខ្លួនដាក់ស្តែងដូចជាការធ្វើឯកជនូបនីយកម្មសហគ្រាសរដ្ឋរួមមាន៖រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញកំពង់ផែស្វយ័តក្រុងព្រះសីហនុនិងកំពង់ផែស្វយ័តភ្នំពេញជាដើម ។
- បង្កើតការងារ៖ទន្ទឹមនឹងនេះនៅពេលក្រុមហ៊ុនបោះផ្សាយទទួលបានទុនបន្ថែមសម្រាប់ពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួនតម្រូវការបុគ្គលិកសម្រាប់បំពេញការងារបន្ថែមគឺពិតជាមិនអាចខ្វះបានដែលជាផ្នែក មួយ ក្នុងការជំរុញកំណើនភាពមានការងារធ្វើនៅក្នុងស្រុកក៏ដូចជា សេដ្ឋកិច្ចជាតិទាំងមូលផងដែរ ។
- ការប្រមូលផ្តុំទុន៖ អ្នកមានទុនតិចក៏អាចវិនិយោគ នៅក្នុងទីផ្សារមូលបត្របានដែរ ដែលវាផ្តល់លទ្ធភាព ដល់ក្រុមអ្នកមានទុនតិចអាចកៀរគរ និងប្រមូលផ្តុំសម្រាប់វិនិយោគ។ ដូច្នេះ ទុនតិចត្រូវបានប្រមូលផ្តុំ សម្រាប់អ្នកត្រូវការទុននៅក្នុងទីផ្សារមូលបត្រដែលធ្វើឱ្យចរន្តសាច់ប្រាក់ មានភាពរស់រវើកជាជាងការទុក សាច់ប្រាក់នៅមួយកន្លែង ឬ វិនិយោគជាមួយទ្រព្យដែលគ្មានផលិតកម្មដូចជា មាសពេជ្រជាដើម ។
- ទីផ្សារមូលបត្រ៖ ធ្វើឱ្យមានលំហូរសាច់ប្រាក់ពីក្រុមហ៊ុនដែលត្រូវការដើមទុន ទទួលបានមូលធនដោយផ្ទាល់ពីវិនិយោគិន។ទីផ្សារមូលបត្រ ធ្វើឱ្យក្រុមហ៊ុនមានលទ្ធភាពពង្រីកអាជីកម្មរបស់ខ្លួនដូចនេះផលិតកម្មក៏កើនឡើង ហើយប្រាក់ចំណូលក៏កាន់តែច្រើន មានន័យថាផលិតផលក្នុងស្រុកមានកំណើន ដែលចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។ វិស័យនានាក៏មានការរីកចម្រើនដោយភាគហ៊ុនិកដើម អាចលក់ភាគហ៊ុនរបស់ខ្លួនក្នុងថ្លៃខ្ពស់ នឹងយកទៅវិនិយោគក្នុងវិស័យថ្មី។ ចំណូលជាតិមានការកើនឡើង ព្រោះអាជីវកម្មរបស់ក្រុមហ៊ុនរីកចម្រើន នោះក្រុមហ៊ុននឹងត្រូវបង់ពន្ធកាន់តែច្រើន។ទីផ្សារភាគហ៊ុន គឺជាសូចនាករមួយដែលអាចឱ្យយើងព្យាករណ៍ពីស្ថានភាពសេដ្ឋកិច្ចជាតិពេលអនាគត តាមរយៈ ការប្រែប្រួលសន្ទស្សន៍ផ្សារបច្ចុប្បន្ន។ ជំរុញឱ្យមានការវិនិយោគបន្ថែមរបស់ក្រុមហ៊ុន និងបង្កើនការងារក្នុងស្រុក ទាក់ទាញឱ្យមានការវិនិយោគដោយផ្ទាល់ពីបរទេស។


Securities
Investment
billion
companies
year
equity
business
Group
trillion
contract
approximately
Company
well sector
Holding
Yang



# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវអស់មួយរយៈកន្លងមក ក្រុមរបស់យើងខ្ញុំ បានប្រមូលផ្តុំនូវព័ត៌មានសំខាន់ៗជាច្រើន ទុកជាទុនដើម្បីធ្វើការវិភាគ ស្ទាបស្ទង់ វាស់វែង និង វាយតម្លៃ ពីដំណើរការបោះផ្សាយ មូលបត្ររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ក្នុងនោះដែរ នាងខ្ញុំក៏បានសង្កេតឃើញពីចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដែលកើតមានឡើងដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការសម្តែងនូវការគាំទ្រចំពោះ ប្រព័ន្ធផ្សព្វផ្សាយថ្មីនេះដើម្បីលើកកម្ពស់ការយល់ដឹងអំពីមូលបត្រ ក្នុងចំណោមវិនិយោគិននានា ដែលមានសក្តានុពល ។
- តម្លៃភាគហ៊ុនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងរយៈពេល ១០ឆ្នាំ ចាប់ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២២ មានការប្រែប្រួលជាវិជ្ជមាន ដោយក្នុងនោះតម្លៃភាគហ៊ុនបានកើនឡើងពី ៦៣០០រៀល ក្នុងមួយហ៊ុន ដែលជាឆ្នាំបោះផ្សាយដល់ទៅតម្លៃ ៧៥៦០រៀលក្នុងមួយហ៊ុន គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ដែលមានកំណើនប្រមាណ ២០%។
- របាយការណ៍ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលចេញផ្សាយនៅដើមខែមេសា ឆ្នាំ ២០១៤ បានបង្ហាញថា ក្រុមហ៊ុនបានទទួលចំណូលប្រមាណ៣៨ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៣ ដែលកើនឡើង១២ភាគរយ បើធៀបនឹង ឆ្នាំ២០១២។ ប្រាក់ចំណេញសុទ្ធរបស់រដ្ឋាករទឹក ស្វយ័តក្រុងភ្នំពេញមាន ចំនួនជិត១០លានដុល្លារអាមេរិក។
- មានវិធានការទប់ស្កាត់ និងវិធីសាស្ត្រស្រូបទាញអ្នកវិនិយោគយ៉ាងមានប្រសិទ្ធភាព
- ផ្តល់ប្រយោជន៍ និងប្រាក់ចំណេញដល់អ្នកវិនិយោគ និងផ្តល់ជាមូលនិធិសម្រាប់អភិវឌ្ឍប្រទេសជាតិថែមទៀតផង។
- វិស័យមូលបត្រ បានធ្វើឱ្យអង្គភាពមានលទ្ធភាពពង្រីកអាជីកម្មរបស់ខ្លួន ដូចនេះផលិតកម្មក៏កើនឡើងហើយមានប្រាក់ចំណូលក៏កាន់តែច្រើន ដែលចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។
- មានប្រព័ន្ធបច្ចេកវិទ្យាទំនើប ក្នុងការរក្សាទុកមូលបត្រដោយសុវត្ថិភាព គឺមានប្រព័ន្ធអេឡិចត្រូនិច និងSystem សម្រាប់ធ្វើការរក្សាទុកមូលបត្រឬទូទាត់សាច់ប្រាក់។
- ការផ្តល់ទិន្នន័យច្បាស់អំពីទីផ្សារតាមរយៈគេហទំព័រ ការផ្សព្វផ្សាយ និងលិខិតបណ្ណនានាដើម្បីធ្វើឱ្យវិនិយោគិនមានភាពងាយស្រួល ក្នុងការសម្រេចចិត្តវិនិយោគ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ភាពខ្សោយរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រនីមួយៗតែងតែលេចឡើងមានជានិច្ច មិនថាការបោះផ្សាយមូលបត្រនោះមានភាពរីកចម្រើន ឬល្បីល្បាញខ្លាំងក៏ដោយ នៅតែមានចំណុចមិនល្អខ្លះដែលកើតមាន។ ដោយមើលឃើញពីចំណុច ខ្វះចន្លោះបន្តិចបន្តួច នាំឱ្យលេចឡើងជាចំណុចខ្សោយដូចជា៖

- មានអសាធនីយភាពនៃក្រុមហ៊ុន ការកេងបន្លំផ្ទៃក្នុងនៃបញ្ជីគណនេយ្យ សកម្មភាពជួញដូរផ្ទៃក្នុងជាដើម។

- អស្ថេរភាពនៃតម្លៃមូលបត្រ ដែលប្រជាជនមានដើមទុនមធ្យមមានអាទិភាពទាបជាង អ្នកវិនិយោគសហគ្រាស ក្រុមហ៊ុនធំៗដែលមានដើមទុនច្រើនជាង
- ការគំរាមកំហែងនៃការលេចឡើងនៅដៃគូប្រកួតប្រជែងថ្មីដែលធ្វើឱ្យតម្រូវការរបស់អ្នកទិញនៅលើទីផ្សារមានកម្រិត។
- ការយល់ដឹងទៅលើវិស័យមូលបត្រសម្រាប់ប្រជាជនកម្ពុជានៅមានកម្រិត ព្រោះវិស័យនេះមិនទាន់ទូលំទូលាយ
- ផលវិបាកនៃប្រជាពលរដ្ឋដែលមានការវិនិយោគដោយមិនបានបែងចែកអោយបានច្បាស់លាស់យកថវិការទៅវិនិយោគច្រើនជាង ការប្រកបអាជីវកម្មជាអចិន្ត្រៃយ៍។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក ក្រុមនាងខ្ញុំពិតជាទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត ដែលពាក់ព័ន្ធនឹងការជួញដូរ និងការបោះផ្សាយមូលបត្រនៅប្រទេសកម្ពុជា។ លើសពីនេះ ក៏បានយល់ច្បាស់ពីសារៈប្រយោជន៍នៃការជួញដូរមូលបត្រចំពោះសេដ្ឋកិច្ចជាតិ ដោយយើងសង្កេតឃើញថា វិស័យមូលបត្រជាវិស័យថ្មីមួយសម្រាប់ប្រទេសកម្ពុជា ដែលអាចផ្តល់អត្ថប្រយោជន៍ជាច្រើនចំពោះវិនិយោគិន និងក្រុមហ៊ុនសហគ្រាសនានាផងដែរ។ នៅក្នុងនេះផងដែរ ក៏បានរៀបរាប់បង្ហាញពីទ្រឹស្តីផ្សេងៗដែលទាក់ទងនឹងប្រវត្តិនៃការបោះផ្សាយ និងការជួញដូរមូលបត្រ ថែមទាំងបានពណ៌នាអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ជាពិសេសគឺ គោលនយោបាយ ចក្ខុវិស័យ និងបេសកកម្ម។ ក្រៅពីនេះក៏ឃើញមានវិនិយោគិនមួយចំនួនកំពុងតែងាកមកយកចិត្តទុកដាក់ចំពោះវិស័យមូលបត្រ ដែលកំពុងមានការកើនឡើងជាលំដាប់ ហើយទីផ្សារមូលបត្រនេះក៏ជាប្រភពមូលធនមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនៃទីផ្សារនេះក៏នៅតែមានបញ្ហាខ្លះៗ បង្កជាឧបសគ្គចំពោះការអភិវឌ្ឍ ដោយសារតែវិនិយោគិនមួយចំនួនតូចនៅមិនទាន់យល់ពីវិស័យមួយនេះច្បាស់ ម្យ៉ាងក៏មិនទាន់សម្របខ្លួនឱ្យយល់ដឹងពីគុណសម្បត្តិ និងគុណវិបត្តិ ហើយឈានដល់ការវិនិយោគទាំងប្រថុយប្រថានទៀតផង។

អាស្រ័យដូចនេះ ទើបក្រុមនាងខ្ញុំបានសម្របសម្រួលចងក្រងឯកសារនេះឡើង សម្រាប់ទុកជាចំណេះដឹងថ្មីមួយផ្នែកក្នុងវិស័យមូលបត្រ ក៏ដូចជាចំណេះដឹងសម្រាប់ចែកចាយជូនដល់ក្រុមនិស្សិតសិស្សានុសិស្ស និងបុគ្គលគ្រប់រូបដែលមានបំណងចង់វិនិយោគលើវិស័យមូលបត្រ និងងាកមកចាប់អារម្មណ៍ឱ្យបានច្រើន ដែលជាផ្នែកមួយជួយជំរុញកំណើនសន្ទុះវិស័យមូលបត្រនេះឱ្យរីកសុះសាយទៅថ្ងៃអនាគត។

## ៥.២. ការផ្តល់អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមក ទីផ្សារមូលបត្រកម្ពុជាមានចំណុចខ្វះខាតខ្លះៗ ហើយដើម្បីចូលរួមចំណែកធ្វើឱ្យវិស័យនេះកាន់តែរីកចម្រើន និងដំណើរការប្រកបដោយសុវត្ថិភាព ក្រុមយើងខ្ញុំសុំបញ្ចេញមតិដូចតទៅ៖

- រាល់សហគ្រាសដែលមានការបោះផ្សាយគួរតែ រឹតបណ្តឹងបទញ្ញានានាអោយមានភាពម៉ត់ចត់ ជាពិសេសចរិតលក្ខណៈនៃបុគ្គលនីមួយៗជៀសវាងអំពើពុករលួយកើតមានឡើង
- អង្គភាពគួរតែកំណត់តម្លៃណាមួយដែលសមស្រប និងទទួលយកបាន រួមទាំងសម្រាប់អ្នកវិនិយោគដែលមានដើមទុនតិច មានលទ្ធភាពទិញបានច្រើនស្មើដូចអ្នកវិនិយោគមានដើមទុនខ្ពស់ផងដែរ
- អង្គភាពគួរតែរក្សានៅទំនុកចិត្ត កេរ្តិ៍ឈ្មោះ និងសុវត្ថិភាពនានានៅក្នុងការជួញដូរ និងរក្សារតម្លៃមួយដែលសមល្មម ដើម្បីរក្សានៅអតិថិជនក្នុងការទិញ ទោះបីមានការដៃដូរច្រើនយ៉ាងណាក៏ដោយ

- រាជរដ្ឋាភិបាល គួរយកចិត្តទុកដាក់ និងផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលចំពោះវិស័យនេះ ឱ្យទូលំទូលាយ ដើម្បីអោយប្រជាជនងាកមកចាប់អារម្មណ៍លើវិស័យ និងចូលរួមក្នុងការវិនិយោគ ឱ្យបានច្រើន ដែលធ្វើអោយវិស័យនានាក៏មានការរីកចម្រើន ដោយភាគហ៊ុនដើម អាចលក់ភាគហ៊ុនរបស់ខ្លួនក្នុងតម្លៃខ្ពស់ និងយកទៅវិនិយោគក្នុងវិស័យថ្មី
- គួរតែមានបង្កើនកម្មវិធីផ្សេងៗជាច្រើន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដែលទាក់ទងក្នុងជួញដូរ និងថវិការដែលត្រូវយកមកវិនិយោគ។

# ឯកសារយោង

# ឯកសារយោង

## សៀវភៅ៖

- ផ្សារមូលបត្រកម្ពុជា

## គេហទំព័រ៖

- [1] https://www.csx.com.kh
- [2] https://www.csx.com.kh
- [3] https://youtu.be/iiZns7_QUiE?si=Nzur-_VkS2sfW8Rq
- [4] *វិស័យមូលបត្រនៅកម្ពុជា* Page 12
- [5] https://youtu.be/iiZns7_QUiE?si=Nzur-_VkS2sfW8Rq
- [6]https://www.linkedin.com/pulse
- [7]conomy.ams.com.kh
- [8] https://buykhmerbook.com/archives/130936
- [9] *ដកស្រង់ចេញពីវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ ជួន ណាត (1967 p.1088)*
- ₁[0]https://buykhmerbook.com/archives/130936

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ